**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវលើអំពើអនីត្យានុកូល

## (ករណីសំណង់ជាប់នឹងដី)

ស្រាវជ្រាវពីថ្ងៃទី០២ មេសា ២០១៨ ដល់ថ្ងៃទី៣១ ឧសភា ២០១៨

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ក. រ៉ាត់ សោភា**

**ក. តាន់ប៉ា គីរីរស្មី**

សាស្ត្រាចារ្យណែនាំ

**លោក គង់ សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៨

ឆ្នាំចូលរៀន ២០១៤

ឆ្នាំសរសេរសារណា ២០១៨

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវលើអំពើអនីត្យានុកូល

# (ករណីសំណង់ជាប់នឹងដី)

ស្រាវជ្រាវពីថ្ងៃទី០២ មេសា ២០១៨ ដល់ថ្ងៃទី៣១ ឧសភា ២០១៨


| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ក. រ៉ាត់ សោភា** | លោក **គង់ សុភ័ក្ត្រ** |
| **ក. តាន់ប៉ា គីរីរស្មី** | |



| | | |
|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលរៀន | ២០១៤ |
| ជំនាន់ទី ១៨ | ឆ្នាំសរសេរសារណា | ២០១៨ |

# **សេចក្តីថ្លែងអំណរគុណ**

ជាបឋមយើងខ្ញុំទាំងពីរនាក់ឈ្មោះ **រ៉ាត់ សោភា** (ក្រុម L4C1) និង **តាន់ប៉ា គិរីរស្មី** (ក្រុម L4A2) ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ឆ្នាំទី៤ ជំនាន់ទី១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៤-២០១៨ ។

## **យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

**លោកឪពុក** និង **អ្នកម្តាយ**ជាទីគោរព ដែលមាននូវមហាឧបការគុណដ៏ឧត្តុង្គឧត្តម និងធំធេងបំផុតគ្មានអ្វីប្រៀបផ្ទឹម និងមិនអាចបំភ្លេចបានឡើយ ព្រោះលោកទាំងពីរជាអ្នកមានគុណដោយបានផ្តល់កំណើត ចិញ្ចឹម បីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅ ព្រមទាំងទំនុកបម្រុងសព្វសារពើទាំងអស់ឲ្យកូនតាំងពីតូចរហូតដល់ធំ ហើយលោកទាំងពីរបានអប់រំ ណែនាំ និងទូន្មានប្រៀនប្រដៅកូនឲ្យចេះដឹងខុសត្រូវធ្វើជាមនុស្សល្អនៅក្នុងសង្គម។ ក្រៅពីនេះ លោកទាំងពីរក៏បានជំរុញទឹកចិត្តឲ្យកូនខិតខំសិក្សារៀនសូត្រដោយបានបញ្ជូនកូនទៅរៀននៅសាលារៀន ព្រមទាំងឧបត្ថម្ភកូនគ្រប់បែបយ៉ាង ទាំងកំលាំងកាយ កំលាំងចិត្ត និងសម្ភារៈរហូតដល់កូនរៀនចប់ដោយជោគជ័យ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយកម្លាំងចិត្តក្នុងការដឹកនាំ គ្រប់គ្រង ជ្រោមជ្រែង និងបង្ហាត់បង្រៀនយើងខ្ញុំឲ្យទទួលបាននូវចំណេះដឹងយ៉ាងច្រើនកន្លងមកនេះ។

**លោកសាស្ត្រាចារ្យ គង់ សុភ័ក្ត្រ** ដែលជាសាស្រ្តាចារ្យណែនាំដោយលោកបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងចំណាយពេលវេលាផ្ទាល់ខ្លួនដ៏មានតម្លៃក្នុងការជួយពន្យល់ណែនាំ ផ្តល់មតិយោបល់ល្អៗ និងផ្តល់ឯកសារមួយចំនួន ព្រមទាំងជួយកែតម្រូវយ៉ាងយកចិត្តទុកដាក់បំផុតរហូតបានធ្វើឲ្យសារណាមួយនេះបានលេចចេញជារូបរាង។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីរ សូមសម្តែងសេចក្តីគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាពិសេសសូមប្រសិទ្ធិពរជ័យ សិរីមង្គល និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិនៅក្នុងលោកទាំងឡាយឲ្យតាមជួយថែរក្សាលោកអ្នកដែលមានគុណទាំងឡាយឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនសុភមង្គល និងជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# អារម្ភកថា

ក្រោយពីបានបន្តការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំមក យើងខ្ញុំបានសិក្សាស្រាវជ្រាវលើមុខវិជ្ជាជាច្រើន ទាំងផ្នែកឯកជន និងសាធារណៈ។ ដើម្បីស្របទៅតាមកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ យើងខ្ញុំបានសម្រេចចិត្តសរសេរសារណាបញ្ចប់ការសិក្សា ដោយបានជ្រើសរើសយកប្រធានបទមួយអំពី **ការទទួលខុសត្រូវលើអំពើអនីត្យានុកូល (ករណីសំណង់ជាប់នឹងដី)** នេះដោយយោងទៅតាមច្បាប់ ការសិក្សាកន្លងមក និងសាស្រ្តាចារ្យដែលបានចូលរួមផ្តល់ជាយោបល់ល្អៗសម្រាប់យើងខ្ញុំដើម្បីឲ្យលេចចេញជាស្នាដៃនេះលេចជារូបរាងឡើង ទុកជាឯកសារមួយដែលមានសារៈសំខាន់ និងអត្ថប្រយោជន៍សម្រាប់និស្សិតជំនាន់ក្រោយៗអាចយកទៅសិក្សារៀនសូត្រទៅអនាគត បើទោះបីជាមានគុណប្រយោជន៍តិចក្តី ច្រើនក្តី។

ស្នាដៃមួយនេះជាស្នាដៃដំបូងមួយចំពោះយើងខ្ញុំទាំងពីរដែលជានិស្សិត ដោយបានខិតខំតស៊ូ ព្យាយាមសិក្សាស្រាវជ្រាវ ត្រងត្រាប់ស្តាប់នូវរាល់ការបង្ហាត់បង្រៀនណែនាំរបស់សាស្រ្តាចារ្យទាំងអស់ និងបានជួបប្រទះនូវការលំបាកជាច្រើនក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធ ព្រមទាំងទទួលបាននូវការពន្យល់ណែនាំ និងកែតម្រូវយ៉ាងយកចិត្តទុកដាក់ពីសាស្រ្តាចារ្យ **គង់ សុភ័ក្រ្ត** ។

ជាការពិតណាស់ឯកសារមួយនេះ មិនទាន់មានភាពល្អឥតខ្ចោះនោះទេដែលវាអាចនៅមានចំណុចខ្វះខាតមួយចំនួនដោយមិនបានធ្វើការស្រាវជ្រាវឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ប៉ុន្តែយើងខ្ញុំក៏សង្ឃឹមថា សារណាមួយនេះអាចរួមចំណែកនៅក្នុងការសិក្សារបស់និស្សិតជំនាន់ក្រោយ។

ជាទីបញ្ចប់ យើងខ្ញុំនឹងទន្ទឹងរង់ចាំទទួលយកនូវរាល់មតិរិះគន់ពីគ្រប់មជ្ឈដ្ឋាននានាក្នុងគោលបំណងដើម្បីស្ថាបនា និងកែលម្អទៅលើរាល់កំហុសឆ្គងទាំងឡាយពីសំណាក់សាស្រ្តាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានទាំងឡាយដោយក្តីគោរពរាប់អាន។

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........................................................................ ១

១.១ សញ្ញាណទូទៅនៃអំពើអនីត្យានុកូល ........................................ ៣

១.១.១ លក្ខខណ្ឌនៃការទទួលខុសត្រូវលើអំពើអនីត្យានុកូល .......................... ៤

១.១.១.១ អំពើបំពានដោយកំហុស (កំហុសចេតនា ឬអចេតនា) ........................ ៤

១.១.១.២ អំពើបំពានដោយខុសច្បាប់ ........................................ ៦

១.១.១.៣ អំពើបណ្តាលឲ្យមានការខូចខាត ........................................ ៦

១.១.១.៤ ទំនាក់ទំនងរវាងអំពើបំពាន និងការខូចខាត ................................ ៧

១.១.២ សមត្ថភាពក្នុងការទទួលខុសត្រូវ ........................................ ៨

១.១.៣ អាជ្ញាយុកាលនៃសិទ្ធិទាមទារសំណង ........................................ ៨

១.២ សញ្ញាណទូទៅនៃសំណង់ជាប់នឹងដី ........................................ ៩

២.១ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលករណីសំណង់ជាប់នឹងដីក្នុងអំឡុងពេលសាងសង់ ........................................ ១១

២.១.១. ភាគីដែលពាក់ពន្ធ័នឹងអំពើអនីត្យានុកូល ........................................ ១២

២.១.២ ភាគីដែលត្រូវទទួលខុសត្រូវលើព្យសនកម្ម ........................................ ១២

២.១.២.១ ករណីជារូបវន្តបុគ្គល ........................................ ១២

២.១.២.២ ករណីជានីតិបុគ្គល ........................................ ១៥

២.២ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលករណីសំណង់ជាប់នឹងដីក្រោយពេលសាងសង់ ........................................ ១៨

២.២.១ ភាគីដែលត្រូវទទួលខុសត្រូវលើព្យសនកម្ម ........................................ ១៨

២.២.១.១ ករណីមិនទាន់ប្រគល់សំណង់ ........................................ ១៨

២.២.១.២ ករណីប្រគល់សំណង់រួចរាល់ ........................................ ១៩

២.៣ លក្ខខណ្ឌនៃការទទួលខុសត្រូវករណីសំណង់ជាប់នឹងដី ........................ ២២
២.៣.១ ករណីការបាក់ស្រុត ឬដួលរលំសំណង់ ឬអាគារ ........................ ២២
២.៣.១.១ វិការៈនៃការសាងសង់ ........................ ២២
២.៣.១.២ ការធ្វេសប្រហែសនៃការសាងសង់ ........................ ២៣
២.៣.២ ករណីអគ្គីភ័យ ........................ ២៣
២.៣.២.១ សំណង់ដែលមានម្ចាស់គ្រប់គ្រងថែរក្សា ........................ ២៣
២.៣.២.២ ប្រភពនៃអគ្គីភ័យ ........................ ២៤
២.៣.៣ ករណីការខូចខាត ឬប៉ះពាល់ដល់អ្នកជនៃ ........................ ២៤
២.៤ ការរួចផុតពីការទទួលខុសត្រូវ ........................ ២៤
២.៤.១ ការការពារជាធម្មនុរូប និង ស្ថានភាពចាំបាច់ ........................ ២៥
២.៤.២ អសមត្ថភាពក្នុងការទទួលខុសត្រូវ ........................ ២៥
២.៤.៣ កំហុសទាំងស្រុងរបស់ជនរងគ្រោះ និង ការព្រមព្រៀងពីជនរងគ្រោះ ........ ២៦
២.៤.៤ ករណីប្រធានសក្តិ ........................ ២៦
សេចក្តីសន្និដ្ឋាន ........................ ២៨
អនុសាសន៍ ........................ ៣០
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ច្បាប់ គឺជាគោលការណ៍គ្រឹះមួយនៅក្នុងប្រទេសមួយដែលចាំបាច់តម្រូវឲ្យមានគ្រប់ប្រទេស ដើម្បីងាយស្រួលនៅក្នុងការរៀបចំ និងគ្រប់គ្រងប្រទេសទាំងមូល។ នៅក្នុងប្រទេសមួយមានច្បាប់មួយផ្សេងពីគ្នាដែលគេបង្កើតឡើងស្របទៅតាមបរិបទ និងប្រពៃណីវប្បធម៌របស់ប្រទេសមួយ ហើយការតាក់តែងច្បាប់មានលក្ខណៈខុសពីគ្នាដោយផ្អែកទៅតាមទីតាំងភូមិសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់ ការរស់នៅ ស្ថានភាពសង្គម និងប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗ។

នៅក្នុងប្រទេសកម្ពុជាយើងក៏មានការបង្កើតនូវច្បាប់ជាច្រើន តែវាមិនមែនជាការងាយស្រួលក្នុងការតាក់តែងច្បាប់ឡើងនោះដែរ។ ព្រោះច្បាប់ត្រូវបានបង្កើតឡើងដោយមានការឯកភាពយ៉ាងច្បាស់លាស់រវាងប្រមុខរដ្ឋាភិបាល និងការព្រមព្រៀងអនុម័តត្រឹមត្រូវទៅតាមការកំណត់របស់ប្រទេសនីមួយៗ និងស្របទៅតាមស្ថានភាពរបស់ប្រទេសនោះទើបមានសុពលភាពអាចយកមកប្រើប្រាស់បានយ៉ាងពេញលេញបាន។ ច្បាប់បង្កើតឡើងមិនមែនដើម្បីជាផលប្រយោជន៍របស់បុគ្គលណាមួយនោះទេ តែដើម្បីការពារទៅដល់សាធារណៈជនទាំងឡាយនូវសិទ្ធិនិងផលប្រយោជន៍របស់ពួកគេ។ មិនតែប៉ុណ្ណោះទេ ច្បាប់ក៏ជាផ្នែកមួយសម្រាប់ប្រើប្រាស់នៅក្នុងការដាក់ទោស និងពិន័យទៅលើបុគ្គលដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់ទទួលខុសត្រូវទៅលើអំពើរបស់ខ្លួន។ ច្បាប់របស់កម្ពុជាយើងបានបែងចែកនូវស្ថានទម្ងន់ទោសក្នុងការទទួលខុសត្រូវនេះជា ការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ និងការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី។

ការទទួលខុសត្រូវខាងព្រហ្មទណ្ឌនេះមានលក្ខណៈធ្ងន់ធ្ងរជាងខាងរដ្ឋប្បវេណី ដោយសារតែការទទួលខុសត្រូវអាចត្រូវជាប់ពន្ធនាគារទៅតាមទម្ងន់ទោសក្នុងរយៈពេលវែង ខ្លី ឬ អស់មួយជីវិតផងដែរ។ រីឯការទទួលខុសត្រូវរដ្ឋប្បវេណីវិញ អ្នកប្រព្រឹត្តត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនតាមរយៈការសងសំណងការខូចខាតទៅកាន់ជនរងគ្រោះ ឬអ្នកគ្រោះ ។

ការទទួលខុសត្រូវទៅលើកំហុសដែលខ្លួនបានប្រព្រឹត្តនេះ នៅក្នុងន័យច្បាប់បានហៅថាជាការទទួលខុសត្រូវលើអំពើអនីត្យានុកូល។ អំពើអនីត្យានុកូល មិនមែនមានតែការទទួលខុសត្រូវចំពោះការខូចខាតដែលកើតចេញពីកំហុសដោយផ្ទាល់របស់អ្នកប្រព្រឹត្តឡើយ។ ការខូចខាតដែលកើតចេញអំពីទ្រព្យសម្បត្តិ ឬ ការគ្រប់គ្រង ក៏មូលហេតុដែលនាំឲ្យមានការទទួលខុសត្រូវដែរ។ ទោះ

យ៉ាង ដូចជាការទទួលខុសត្រូវចំពោះសំណង់ជាប់នឹងដីជាដើម។ ដែលករណីនេះ ទាមទារឲ្យមានការទទួលខុសត្រូវផងដែរ ទោះបីជាការខូចខាតមិនបានកើតចេញពីអំពើដោយផ្ទាល់របស់ម្ចាស់សំណង់ក៏ដោយ។

ដើម្បីយល់កាន់តែច្បាស់ និងស៊ីជម្រៅទៅលើចំណោទបញ្ហាដែលកើតមានទាក់ទងនឹងប្រធានបទអំពី "**ការទទួលខុសត្រូវលើអំពើអនីត្យានុកូល (ករណីសំណង់ជាប់នឹងដី)**" យើងខ្ញុំសូមចូលខ្លួនមកធ្វើការបកស្រាយ ដោយធ្វើការបែងចែកជាពីរជំពូក គឺ ជំពូកទី១ ស្តីពីសញ្ញាណទូទៅនៃការទទួលខុសត្រូវចំពោះសំណង់ជាប់នឹងដី និងជំពូកទី២ ស្តីពីព្យសនកម្មដោយសំណង់ជាប់នឹងដី។

# ជំពូកទី១

# សញ្ញាណទូទៅនៃការទទួលខុសត្រូវ

# ចំពោះសំណង់ជាប់នឹងដី

# ជំពូកទី១

# សញ្ញាណទូទៅនៃការទទួលខុសត្រូវចំពោះសំណង់ជាប់នឹងដី

ការទទួលខុសត្រូវចំពោះសំណងជាប់នឹងដី កើតមានឡើងដោយអំពើអនីត្យានុកូល (១.១) ដែលបង្កឡើងដោយសំណងជាប់នឹងដី (១.២)។

## ១.១ សញ្ញាណទូទៅនៃអំពើអនីត្យានុកូល

អំពើអនីត្យានុកូល គឺជាប្រភពមួយនៃកាតព្វកិច្ចដែលកើតឡើងក្រៅឆន្ទៈរបស់ភាគីនៃកាតព្វកិច្ច ឬជាការទទួលខុសត្រូវក្រៅកិច្ចសន្យាលើការសងនូវខូចខាត ក្នុងករណីដែលបានបំពានសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃដោយខុសច្បាប់ ដោយចេតនាឬដោយអចេតនា ដែលនាំឲ្យបុគ្គលដែលមានសិទ្ធិនៅក្នុងការទាមទារនូវសំណងលើការខូចខាតចំពោះព្យសនកម្ម ដែលបុគ្គលណាមួយបានប្រព្រឹត្តមកលើខ្លួន។ ក្នុងសន្ទានុក្រមនៃក្រមរដ្ឋប្បវេណី បានឲ្យនិយមន័យនៃអំពើអនីត្យានុកូលថា ជាអំពើដែលបំពានដោយខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃដោយកំហុសចេតនា ឬអចេតនា។

កាតព្វកិច្ចតាមន័យផ្លូវច្បាប់ គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ឬច្រើននាក់ដោយបុគ្គលណាម្នាក់ ដែលបានកំណត់ឲ្យមាននូវករណីកិច្ចមួយចំនួនចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀតដែលហៅថា កូនបំណុល ក្នុងការបំពេញនូវតាវកាលិក (អ្វីៗដែលអ្នកជាប់កាតព្វកិច្ចត្រូវបំពេញ) អ្វីមួយដើម្បីជាផលប្រយោជន៍សម្រាប់បុគ្គលម្នាក់ផ្សេងទៀតដែលជា ម្ចាស់បំណុល (ក្រមរដ្ឋប្បវេណី, ៣០៨)។ ប្រភពនៃកាតព្វកិច្ចកើតឡើងដោយសារតែកិច្ចសន្យា ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុដោយអំពើអនីត្យានុកូល និងដោយបញ្ញត្តិនៃច្បាប់[1]។ ដោយឡែកកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យា និងដោយសកម្មភាពឯកតោភាគី គឺជាកាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី និងកាតព្វកិច្ចដែលកើតចេញដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុដោយអំពើអនីត្យានុកូល និងដោយបញ្ញត្តិនៃច្បាប់ គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់[2]។

---

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣០៩ វាក្យខណ្ឌទី១។

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣០៩ វាក្យខណ្ឌទី២ និងទី៣។

### ១.១.១ លក្ខខ័ណ្ឌនៃការទទួលខុសត្រូវលើអំពើអនីត្យានុកូល

អំពើអនីត្យានុកូល សំដៅទៅលើការទទួលខុសត្រូវដែលមានគោលបំណងធានាឲ្យមានការសងនូវសំណងខូចខាតទៅដល់ជនរងគ្រោះ ឬ អ្នករងគ្រោះ។ ដែលត្រង់នេះ ខុសពីគោលបំណងនៃការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ដែលគោលបំណងដាក់ទោសដល់អ្នកប្រព្រឹត្តបទល្មើស។ ទោះបីជាខុសគ្នារវាងអំពើអនីត្យានុកូល និងព្រហ្មទណ្ឌយ៉ាងក៏ដោយ ដើម្បីកំណត់អំពើណាមួយជាអំពើអនីត្យានុកូល ដែលនាំជនរងគ្រោះ ឬ អ្នករងគ្រោះអាចទាមទារសំណងការខូចខាតបាន ចាំបាច់ត្រូវតែគោរពតាមល័ក្ខខ័ណ្ឌមួយចំនួនដូចជា[3]៖

- អំពើបំពានដោយកំហុស
- អំពើបំពានខុសច្បាប់
- អំពើបណ្តាលឲ្យមានការខូចខាត
- ទំនាក់ទំនងរវាងហេតុផល និងការខូចខាត។

#### ១.១.១.១ អំពើបំពានដោយកំហុស (កំហុសចេតនា ឬអចេតនា)

អំពើដែលបំពានដោយកំហុសត្រូវបានបែងចែកចេញជា ២គឺអំពើបំពានដោយកំហុសចេតនា និងកំហុសអចេតនា។ អំពើនៃកំហុសចេតនា និងកំហុសអចេតនានេះសំដៅទៅលើអំពើដែលត្រូវនឹងចំណុចដូចខាងក្រោម[4]៖

ក- ធ្វើអំពើបំពានដោយព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយទទួលយកការកកើតឡើងនៃលទ្ធផលនោះ។

ខ- ធ្វើអំពើដែល បើតាមការប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬបទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនេះ អាចព្យាករទុកជាមុនអំពីការកកើតនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះដោយសារការធ្វេសប្រហែស ការមិនបានប្រុងប្រយ័ត្ន ហើយទោះបីជាមានករណីកិច្ចជៀងវាងនូវលទ្ធផលនោះក៏ដោយក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ។

[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៣។

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤២។

មិនតែប៉ុណ្ណោះអត្ថន័យកំហុសនេះ ក៏ត្រូវបានកំណត់ទៅលើអាកប្បកិរិយារបស់បុគ្គលម្នាក់ ដោយសារតែការខ្ជីខ្ជា ការធ្វេសប្រហែស ការមិនយកចិត្តទុកដាក់របស់ខ្លួនមិនបានបំពេញករណីយកិច្ចរបស់ខ្លួនដែលបានបង្កឲ្យមានការខូចខាតដល់អ្នកដទៃ ឬអាចជាការភ័ន្តច្រលំក្នុងការប្រព្រឹត្តអ្វីមួយជាអាកប្បកិរិយាគួរបន្ទោសចំពោះបុគ្គលណាម្នាក់ដែលបានបំពានវិធានអ្វីមួយ ដែលបានចែងរួចហើយនោះ[5]។

### ក. កំហុសចេតនា

កំហុសដោយចេតនា មានន័យថាជាការប្រព្រឹត្តអំពើអ្វីមួយដែលជននោះអាចយល់ដឹង ឬព្យាករទុកជាមុនបានថា អំពើរបស់ខ្លួននឹងបង្កើតឲ្យមាននូវលទ្ធផលដែលជាការអន្តរាយ ឬមានការខូចខាតទៅដល់អ្នកដទៃ ហើយខ្លួនព្រមទទួលយកនូវការកើតឡើងនៃលទ្ធផលនេះទោះបីជាគោលដៅនៃអំពើមិនប្រាកដថាត្រូវបង្កឲ្យមានអន្តរាយក្តី។ មិនតែប៉ុណ្ណោះអំពើនោះគេបានយល់យ៉ាងច្បាស់អំពីការកំណត់ទោសដែលមាននៅក្នុងច្បាប់ ប៉ុន្តែជនដែលបង្កនោះនៅតែចង់ឲ្យអំពើនោះកើតមានឡើងដោយមិនគិតពីលទ្ធផលចុងក្រោយនៃអំពើដែលខ្លួនបានប្រព្រឹត្តនោះឡើយ [6]។ ឬជនដែលបង្កឲ្យកើតមាននូវការខូចខាតដល់ជនរងគ្រោះនោះមានឆន្ទៈច្បាស់លាស់ និងដោយបានដឹងសព្វគ្រប់ទៅលើសកម្មភាពរបស់ខ្លួននៅក្នុងការប្រព្រឹត្តថាអាចនឹងមានការខូចខាតកើតឡើង តែនៅតែបន្តសកម្មភាពរបស់ខ្លួនរហូតបានបង្កឲ្យមាននូវព្យសនកម្មកើតមានឡើង ។

### ខ. កំហុសអចេតនា

កំហុសអចេតនា គឺជាកំហុសដែលកើតឡើងដោយការធ្វេសប្រហែស ការខ្ជីខ្ជា ឬការខ្វះការប្រុងប្រយ័ត្នរបស់ជនបង្កដែលបានបណ្តាលឲ្យមានការខូចខាតកើតមានឡើង ដោយសារតែការប្រព្រឹត្ត ឬសកម្មភាពរបស់ខ្លួនដោយមិនអាចព្យាករទុកមុន ឬជៀសវាងបាន ហើយបានបង្កឲ្យមានការខូចខាតទៅដល់ជនរងគ្រោះថែមទៀត ដូចជាកំហុសរបស់អ្នកបើកបររថយន្តដែលបានបើកបរក្នុងល្បឿនហួសកំណត់ ឬបើកបរក្នុងស្ថានភាពស្រវឹងដែលបានបណ្តាលឲ្យជនរងគ្រោះរបួស

[5] ញឹក វុទ្ធី, នីតិកាតព្វកិច្ច (២០១៧), ២៨។

[6] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, រៀបរៀង, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១-២ (រាជធានីភ្នំពេញ, ២០១៣), ៩៣។

ឬស្លាប់ ប៉ុន្តែករណីនេះជនបង្កពុំមានបំណងក្នុងការបើកបុកធ្វើឲ្យជនរងគ្រោះរបួស ឬស្លាប់នោះឡើយ។

### ១.១.១.២ អំពើបំពានដោយខុសច្បាប់

ដោយយោងតាមមាត្រា ៧៤៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានចែងថា "បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃដោយកំហុសចេតនា ឬកំហុសអចេតនាត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ"។

ការបំពានដោយខុសច្បាប់នេះ មិនត្រឹមតែជាការបំពានទៅលើច្បាប់ព្រហ្មទណ្ឌ និងច្បាប់ផ្សេងៗនោះទេ តែបានបំពានទៅលើសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃ ថែមទាំងមានការប៉ះពាល់ទៅដល់វិន័យរបស់សង្គមទៀតផង។ ការបំពានដោយខុសច្បាប់ទាំងនេះទោះបីជាធ្វើការបំពានដោយកំហុសចេតនាក្តី ឬកំហុសអចេតនាក្តី គឺវាសុទ្ធតែជាអំពើដែលខុសនឹងច្បាប់ ក៏ប៉ុន្តែវាក៏មាននូវប្រភេទនៃការបំពានមួយចំនួនដែលបានចាត់ទុកថា មិនមានភាពផ្ទុយនឹងច្បាប់នោះទេ ប្រសិនបើមានការចាត់ចូលទៅក្នុងល័ក្ខខ័ណ្ឌមួយចំនួនដែលនាំឲ្យមានការរួចផុតពីភាពផ្ទុយច្បាប់ ដូចជាអំពើការពារខ្លួនជាធម្មានុរូប ជាដើម[7]។

### ១.១.១.៣ អំពើបណ្តាលឲ្យមានការខូចខាត

ការខូចខាត (ព្យសនកម្ម) មានដូចជាការខូចខាតដែលជាទ្រព្យសម្បត្តិ និងការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ។

ការខូចខាតនេះ គឺជាចំណុចសំខាន់មួយនៅក្នុងការទទួលខុសត្រូវដោយហេតុថា ប្រសិនបើមាននូវកំហុសដែលបានប៉ះពាល់ដល់សិទ្ធិ ឬប្រយោជន៍របស់អ្នកដទៃក៏ដោយ ក៏កាតព្វកិច្ចក្នុងការទទួលខុសត្រូវក៏មិនកើតមានឡើយ បើមិនមានកើតមានឡើងនូវការខូចខាតណាមួយ។ ព្រោះវាមិនមាននូវព្យសនកម្មណាមួយដែលតម្រូវឲ្យមានការជួសជុលនោះទេ។

[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៥៦។

### ក. ការខូចខាតដែលជាទ្រព្យសម្បត្តិ

ការខូចខាតដែលជាទ្រព្យសម្បត្តិ ឬការខូចខាតខាងសម្ភារៈ ជាការខូចខាតទាំងឡាយណាដែលប៉ះពាល់ ឬបំពារបំពានទៅដល់បេតិកភ័ណ្ឌរបស់បុគ្គលណាមួយ ដែលវាអាចស្ថិតក្រោមរូបភាពជាទ្រព្យសម្បត្តិដូចជា ប្រាក់កាស ការបាត់បង់វត្ថុ ឬការបែកបាក់វត្ថុផ្សេងៗ សោហ៊ុយព្យាបាល ការប៉ះពាល់ដល់ការចំណេញ ឬ ប្រាក់ចំណូល អចលនវត្ថុ ឬចលនវត្ថុ ជាដើម។

### ខ. ការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ

ការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ ចែកជា២ទៀត គឺការខូចខាតខាងរាងកាយ និងការខូចខាតខាងស្មារតី។

ការខូចខាតខាងរាងកាយ គឺជាការខូចខាតដែលទាំងឡាយដែលមានការប៉ះពាល់ទៅដល់រូបរាងកាយដែលបានបង្កឲ្យមានការឈឺចាប់ ឬមានស្នាមរបួស ឬសម្ពស្ស ឬអាចជាការប៉ះពាល់ដល់អាយុជីវិតរបស់មនុស្ស និងបូករួមទាំងការខូចខាតខាងសតិអារម្មណ៍ដែលកើតឡើងចំពោះជនរងគ្រោះហើយអាចបង្កជាផលលំបាកក្នុងរយៈពេលកំណត់មួយ ឬអាចពេញមួយជីវិតរបស់ជនរងគ្រោះដែលវាអាចប៉ះពាល់ទៅដល់វិជ្ជាជីវៈការងារ និងជីវភាពឯកជន។ ការខូចខាតនេះត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាលដែលបានចំណាយហើយ ឬសោហ៊ុយព្យាបាលដែលអាចនឹងត្រូវចំណាយនាពេលអនាគតសម្រាប់ផលវិបាកដែលបន្សល់ទុកក្រោយពេលដែលព្យាបាលរួច[8]។

រីឯការខូចខាតខាងសតិអារម្មណ៍ ជាការប៉ះពាល់ខាងសតិអារម្មណ៍ ប្រាជ្ញា ឬការប៉ះពាល់សិទ្ធិក្រៅបេតិកភ័ណ្ឌ តាមរយៈការបំពានលើកិត្តិយស កេរ្តិ៍ឈ្មោះ ជីវភាពឯកជន ឬមនោសញ្ចេតនាសតិអារម្មណ៍ ជាដើម ដែលបានបង្កឲ្យមានផលវិបាកទៅកាន់ជនរងគ្រោះក្នុងរយៈពេលខ្លី ឬវែងទៅតាមស្ថានភាពជាក់ស្តែងដែលក្នុងករណីនេះជនរងគ្រោះអាចទាមទារសំណងការខូចខាតបាន[9]។

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៦១។

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៦២។

### ១.១.១.៤ ទំនាក់ទំនងរវាងអំពើបំពាន និងការខូចខាត

គេអាចហៅទំនាក់ទំនងរវាងអំពើបំពាន និងការខូចខាតដោយក្ដីថា ទំនាក់ទំនងហេតុ និងផល។ ហេតុ សំដៅដល់អំពើបំពានសិទ្ធិ ឬ ផលប្រយោជន៍ ដែលប្រព្រឹត្តឡើងដោយជនបង្ក។ ចំណែកឯ ផលសំដៅដល់ព្យសនកម្មដែលជាលទ្ធផលនៃអំពើបំពាន។ ដើម្បីអាចទាមទារសំណងការខូចខាតចំពោះការប្រព្រឹត្តអំពើបំពានរបស់ជនណាម្នាក់ អ្នកដែលមានបំណងទាមទារសំណងនោះត្រូវបញ្ជាក់ឲ្យឃើញថា ការខូចខាតដែលបានកើតឡើងពិតជាកើតចេញពីអំពើបំពានយ៉ាងពិតប្រាកដដោយភ្ជាប់មកជាមួយនូវភស្តុតាង។

### ១.១.២ សមត្ថភាពក្នុងការទទួលខុសត្រូវ

សមត្ថភាពនៅក្នុងការទទួលខុសត្រូវនេះ សំដៅទៅលើភាពដែលមានសមត្ថភាពគ្រប់គ្រាន់របស់បុគ្គលដែលបានប្រព្រឹត្តដើម្បីវិនិច្ឆ័យអំពីអំពើរបស់ខ្លួន។

ជនដែលមានអាយុក្រោម ១៨ឆ្នាំ និងជនដែលមានសតិមិនគ្រប់គ្រាន់ មិនអាចយល់ដឹង និងវិនិច្ឆ័យអំពីការប្រព្រឹត្តនូវអំពើរបស់ខ្លួនបាន មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនោះទេ[10]។ មានន័យថា ប្រសិនបើជនទាំងពីរប្រភេទនេះ បានប្រព្រឹត្តអំពើអនីត្យានុកូលដែលនាំឲ្យមានការខូចខាតដល់សិទ្ធិ ឬ ផលប្រយោជន៍អ្នកទៃ នោះជនប្រភេទនេះមិនទទួលខុសត្រូវក្នុងការសងសំណងខូចខាតឡើយ។ ប៉ុន្តែមិនមែនមានន័យថា គ្មានអ្នកទទួលខុសត្រូវក្នុងសងសំនងនោះទេ។ អាណាព្យាបាល ឬអ្នកមានករណីយកិច្ចដែលកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យរបស់ជនទាំងពីរប្រភេទខាងលើ ជាអ្នកទទួលខុសត្រូវសងសំណងការខូចខាតដល់ជនរងគ្រោះ ឬ អ្នករងគ្រោះ[11]។

ក៏ប៉ុន្តែ សម្រាប់ជនដែលមិនអាចយល់ដឹង និងវិនិច្ឆ័យអំពីការប្រព្រឹត្តរបស់ខ្លួន នៅតែទទួលខុសត្រូវក្នុងការសងសំណងដោយខ្លួនឯង ប្រសិនបើស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យអំពីការប្រព្រឹត្តរបស់ខ្លួន បានកើតឡើងដោយសារតែកំហុសចេតនា ឬអចេតនារបស់ខ្លួនឯងផ្ទាល់[12]។ ស្ថានភាពមានបែបនេះ មានដូចជាស្រវឹងស្រា ស្រវឹងគ្រឿងញៀន ជាដើម។

---

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៥។

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៦។

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៥ កថាខណ្ឌទី២ វាក្យខណ្ឌទី២។

### ១.១.៣ អាជ្ញាយុកាលនៃសិទ្ធិទាមទារសំណង

កាលណាមានការខូចខាតដោយអំពើអនីត្យានុកូល ជនរងគ្រោះ ឬ អ្នករងគ្រោះមានសិទ្ធិក្នុងការទាមទារនូវសំណងការខូចខាត។ សិទ្ធិនៅក្នុងការទាមទារសំណងនេះដែរ នឹងត្រូវបាត់បង់ ឬទុកជាអសារបង់ ប្រសិនបើជនរងគ្រោះ ឬ អ្នករងគ្រោះមិនបានទាមទារក្នុងអំឡុងពេលណាមួយដែលកំណត់ដោយច្បាប់។ ការបាត់បង់សិទ្ធិបែបនេះ គេហៅថាការរលត់សិទ្ធិដោយផុតអាជ្ញាយុកាលនៃការទាមទារ។

អាជ្ញាយុកាលនៃការទាមទារខាងលើមានរយៈពេល ៣ឆ្នាំ បន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះបានដឹងថា អាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ អំឡុងពេល ១០ឆ្នាំ បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង[13]។

## ១.២ សញ្ញាណទូទៅនៃសំណង់ជាប់នឹងដី

សំណង់ គឺជាផ្នែកមួយនៃផលិតផលគ្រឹះក្នុងខឿនសេដ្ឋកិច្ចជាតិដែលមានតួនាទីសំខាន់ក្នុងការកសាងមូលដ្ឋានសម្ភារៈ បច្ចេកទេសសង្គម ហើយក៏ជាការសម្តែងចេញនូវការអភិវឌ្ឍន៍របស់សង្គមរបស់ប្រទេសនីមួយ។ វាក៏បានដើរតួសំខាន់នៅក្នុងប្រទេសកម្ពុជាដែលជាប្រទេសកំពុងរីកចម្រើនលូតលាស់ផងដែរ មិនតែប៉ុណ្ណោះយើងក៏សង្កេតឃើញមាននូវសំណង់កើតមានឡើងកាន់តែច្រើនឡើងៗនៅទូទាំងប្រទេសដែលមានដូចជាអាគារ ផ្លូវ ស្ពាន ឬសំណង់ដទៃទៀត[14]។ សំណង់ត្រូវបានបែងចែកចេញជា សំណង់ឥដ្ឋបេតុង និងសំណង់មិនមែនឥដ្ឋបេតុង ដែលសំណង់ឥដ្ឋបេតុង សំដៅទៅលើសំណង់ដែលមានប្លង់សេ[15]។ ដោយឡែកនៅក្នុងប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ បានឲ្យនិយមន័យអគារ និងសំណង់ផ្សេងៗ សំដៅដល់អាគារ និងសំណង់ផ្សេងៗដែលសង់ជាប់នឹងដីទោះមាន ឬគ្មានជញ្ជាំង ឬដំបូលក៏ដោយ មានជាអាទិ៍ សណ្ឋាគារ អាផាតមែនខុនដូ ការិយាល័យ រោងចក្រ ឃ្លាំង ផ្សារទំនើប សំណង់អាគារឧស្សាហកម្ម ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ចំណតរថយន្ត។ សំណង់ ឬអាគារមួយអាច

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៦៥។

[14] សួស ចំរើន, គ្រប់គ្រងសំណង់ (២០០៣), ១។

[15] អគ្គនាយកពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សៀវភៅណែនាំស្តីពីពន្ធលើអចលនវត្ថុ (២០១៣), ១១។

មានកម្មសិទ្ធិករម្នាក់ ឬច្រើននាក់ដែលគេហៅថា សហកម្មសិទ្ធិករ ដែលមានសិទ្ធិ និងកាតព្វកិច្ចទៅលើសំណង់ដាច់ដោយឡែកពីគ្នាទៅតាមការទំហំនៃសិទ្ធិកម្មសិទ្ធិរបស់ខ្លួន និងតាមការកំណត់របស់ច្បាប់របស់ប្រទេសកម្ពុជា។ ការបែងចែកសំណង់នេះធ្វើឡើងដើម្បីបង្កលក្ខណៈងាយស្រួលដល់កម្មសិទ្ធិករ និងសហកម្មសិទ្ធិករក្នុងការបំពេញនូវកាតព្វកិច្ចតាមផ្នែកច្បាប់របស់ខ្លួនឲ្យមានប្រសិទ្ធភាព និងបានកំណត់ច្បាស់លាស់ទៅលើកាតព្វកិច្ចរៀងៗខ្លួនដូចជា កម្មសិទ្ធិទៅលើសំណង់ ឬអាគារ ការបង់ពន្ធ និងការទទួលខុសត្រូវលើសំណង់ដែលស្ថិតនៅក្នុងកម្មសិទ្ធិរបស់ខ្លួន ជាដើម។ មិនតែប៉ុណ្ណោះវាក៏បានបង្កនូវភាពងាយស្រួលសម្រាប់ស្ថាប័ន ឬអាជ្ញាធរពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធនឹងសំណង់ជាប់នឹងដីនេះអាចបំពេញតួនាទីរបស់ខ្លួនទៅដោយរលូន និងមានលក្ខណៈឆាប់រហ័សក្នុងការបំពេញតួនាទីជូនប្រជាជន។

# ជំពូកទី២

# ព្យសនកម្មដោយសំណាច់ជាប់នឹងដី

# ជំពូកទី២
# ព្យសនកម្មដោយសំណង់ជាប់នឹងដី

សម្រាប់ព្រះរាជាណាចក្រកម្ពុជា ចំពោះអំពើអនីត្យានុកូលករណីសំណង់ជាប់នឹងដីដោយផ្អែកលើក្រមរដ្ឋប្បវេណី មាត្រា ៧៥៣ គឺជាបញ្ញត្តិដែលចែងអំពីការទទួលខុសត្រូវចំពោះសំណង់ជាប់នឹងដី ។ កាលណាសំណង់ជាប់លើដីដូចជាអាគារ ឬ របងជាដើម បានធ្វើឲ្យអ្នកដទៃមានការខូចខាតក្នុងមាត្រាខាងលើតម្រូវឲ្យម្ចាស់សំណង់ និងអ្នកគ្រប់គ្រងសំណង់ទទួលខុសត្រូវលើសំណងការខូចខាតដោយសាមគ្គី។ ម្ចាស់សំណង់ និងអ្នកគ្រប់គ្រងសំណង់នៅត្រង់ចំណុចនេះមិនបានធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ថាជាម្ចាស់សំណង់ ឬអ្នកគ្រប់គ្រងសំណង់នាអំឡុងពេលណាមួយឡើយ។

ហេតុដូចនេះ ដើម្បីងាយស្រួលក្នុងការស្វែងរកអ្នកទទួលខុសត្រូវលើអំពើអនីត្យានុកូលលើករណីសំណង់ជាប់នឹងដីយើងត្រូវបែងបែងចែកជា២ករណីផ្សេងគ្នា គឺការទទួលខុសត្រូវចំពោះសំណង់ជាប់នឹងដីក្នុងអំឡុងពេលសាងសង់ (២.១) និងក្រោយពេលសាងសង់ (២.២) ។

## ២.១ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលករណីសំណង់ជាប់នឹងដីក្នុងអំឡុងពេលសាងសង់

អំឡុងពេល ជារយៈពេលមួយដែលកំណត់ថា សំណង់ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគីណាមួយ ដូចជា ក្នុងអំឡុងពេលនៃការសាងសង់ និងក្រោយពេលសាងសង់ ភាគីដែលគ្រប់គ្រងលើសំណង់មិនមានលក្ខណៈដូចគ្នានោះទេ។ ការសាងសង់សំណង់ទាំងឡាយការកំណត់អំឡុងពេលនៃការសាងសង់ ឬអំឡុងពេលដែលសាងសង់រួចរាល់ហើយ គឺអាស្រ័យលើការព្រមព្រៀងរបស់ភាគីដែលបានកំណត់នៅក្នុងកិច្ចសន្យាម៉ៅការ ឬកិច្ចសន្យាសាងសង់ផ្សេងៗជាដើម។ សម្រាប់អំឡុងពេលនៃការសាងសង់ គឺជាអំឡុងពេលដែលសំណង់ ឬការសាងសង់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកម៉ៅការ ឬក្រុមហ៊ុនសាងសង់ដែលក្នុងអំឡុងពេលនេះកម្មសិទ្ធិករ ឬម្ចាស់សំណង់មិនទាន់បានគ្រប់គ្រងសំណង់របស់ខ្លួននៅឡើយ ។

### ២.១.១. ភាគីដែលពាក់ពន្ធ័នឹងអំពើអនីត្យានុកូល

ក្នុងការសិក្សាលើការទទួលខុសត្រូវឲ្យបានស៊ីជម្រៅ យើងត្រូវធ្វើបែងចែកឲ្យបានច្បាស់លាស់នូវភាគីទាំងឡាយដែលពាក់ព័ន្ធនឹងអំពើអនីត្យានុកូល។ តទៅនេះយើងខ្ញុំសូមលើកយក ភាគីចំនួនពីរយកមកបកស្រាយគឺ ភាគីដែលទទួលរងព្យសនកម្ម និងភាគីដែលត្រូវទទួលខុសត្រូវលើព្យសនកម្ម។

ចំពោះភាគីដែលទទួលរងព្យសនកម្ម សំដៅទៅលើជនរងគ្រោះ ជាជនដែលទទួលរងការខូចខាតដែលបង្កឡើងដោយអំពើអនីត្យានុកូល ដែលការខូចខាតនោះអាចជាព្យសនកម្មលើផ្នែករូបរាងកាយ ឬផ្នែកសម្ភារៈដូចជាទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃផ្សេងៗជាដើម។

### ២.១.២ ភាគីដែលត្រូវទទួលខុសត្រូវលើព្យសនកម្ម

កាតព្វកិច្ចក្នុងការជួលជុលនូវព្យសនកម្មដែលជនរងគ្រោះបានទទួលរងតាមច្បាប់ គឺជាបន្ទុករបស់បុគ្គលដែលបានប្រព្រឹត្តអំពើដែលនាំឲ្យមានការខូចខាត។ ចំពោះបុគ្គលដែលត្រូវទទួលខុសត្រូវលើសំណងព្យសនកម្មក្នុងអំឡុងពេលសាងសង់នេះអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ហើយលើសពីនេះទៅទៀតអាចជាតតិយជនផ្សេងទៀតដែរ។

#### ២.១.២.១ ករណីជារូបវ័ន្តបុគ្គល

រូបវន្តបុគ្គល ជាមនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល[16]។ គ្រប់បុគ្គលជាមនុស្សជាតិដែលច្បាប់កំណត់គុណភាពជារូបវន្តបុគ្គល។ គ្រប់រូបវន្តបុគ្គលដែលបង្កឲ្យមានការខូចខាតទោះបីដោយមានកំហុសក្តី គ្មានកំហុសក្តី ឬអាចបណ្តាលមកពីការធ្វេសប្រហែស រូបវន្តបុគ្គលនោះត្រូវតែទទួលខុសត្រូវរបស់អំពើរបស់ខ្លួន ហើយស្ថិតក្នុងអំឡុងពេលសាងសង់រូបវន្តបុគ្គលដែលត្រូវទទួលខុសត្រូវលើព្យសនកម្មរួមមានដូចជា អ្នកម៉ៅការសំណង់ កូនជាង តតិយជន។

#### ក. អ្នកម៉ៅការសំណង់

ចំពោះការសាងសង់សំណង់មួយចំនួន កម្មសិទ្ធិករធ្វើការសាងសង់សំណង់ដោយខ្លួនឯង និងការសាងសង់មួយចំនួនធំ កម្មសិទ្ធិករ ឬហៅសាមញ្ញថាម្ចាស់ផ្ទះភាគច្រើនតែងតែរកអ្នកម៉ៅការដើម្បីមកធ្វើការសាងសង់សំណង់របស់ខ្លួន ដោយមានការព្រមព្រៀងគ្នាធ្វើឡើងជាកិច្ចសន្យា

[16] សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លេខ១២៧, ទំព័រ ១៩។

ម៉ៅការ ឬកិច្ចសន្យាសាងសង់ជាលាយលក្ខណ៍អក្សរ។ ខ្លះទៀតមិនបានធ្វើជាកិច្ចសន្យាដែលមានទម្រង់ជាលាយលក្ខណ៍អក្សរឡើយ ដោយធ្វើឡើងដោយផ្ទាល់មាត់ ប៉ុន្តែការសន្យាដោយផ្ទាល់មាត់ភាគច្រើនមិនអាចកើតមានចំពោះប្រភេទកិច្ចសន្យាម៉ៅការ ឬកិច្ចសន្យាសាងសង់ឡើយដោយហេតុថា គូភាគីនៃកិច្ចសន្យាទាមទារឲ្យមានទំនុកចិត្តរវាងគ្នាទៅវិញទៅមក និងដើម្បីជាសម្អាងក្នុងការតតាំងនៅពេលដែលកើតមានវិវាទដោយប្រការណាមួយ។ ដូចនេះប្រសិនបើមិនបានធ្វើជាលាយលក្ខណ៍អក្សរ វាគឺជាផលវិបាកនៅក្នុងការបង្ហាញភស្តុតាង។

ដើម្បីទាមទារឲ្យអ្នកម៉ៅការ ជាបុគ្គលដែលត្រូវទទួលខុសត្រូវលើព្យសនកម្មចំពោះម្ចាស់ការ ឬតតិយជន ទី១ សម្អាងទៅលើ កិច្ចសន្យាម៉ៅការ។ កិច្ចសន្យាម៉ៅការ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថាអ្នកម៉ៅការមានករណីកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាង ទៀតហៅថាម្ចាស់ការមានករណីយកិច្ចផ្តល់កម្រៃចំពោះលទ្ធផលនៃការងារដែលបានធ្វើនោះ[17]។ ទន្ទឹមនឹងនេះ កិច្ចសន្យាម៉ៅការ គឺជាកិច្ចសន្យាដែលយកតម្លៃថ្នូរ និងជាកិច្ចសន្យាទ្វេភាគីដែលគូភាគីនៃកិច្ចសន្យាត្រូវផ្តល់តាវកាលិកឲ្យគ្នាទៅវិញទៅមក។ យោងតាមមាត្រា ៦៥៤ ក្រមរដ្ឋប្បវេណី អ្នកម៉ៅការ មានករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈចំពោះម្ចាស់ការ។ ក្នុងអំឡុងពេលសាងសង់ជារយៈពេលដែលបំពេញការងាររបស់អ្នកម៉ៅការចំពោះម្ចាស់សិទ្ធិ ហើយសំណង់ក៏ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកម៉ៅការ ដូចនេះក្នុងករណីដែល ការសាងសង់សំណង់បណ្តាលឲ្យមានវិការៈ ឬបណ្តាលឲ្យសំណង់ខូចខាត ឬបណ្តាលឲ្យអំពើអនីត្យានុកូលកើតមានឡើងចំពោះតតិយជន ឬទ្រព្យសម្បត្តិផ្សេងៗរបស់តតិយជនដែលជាជនរងគ្រោះ អ្នកម៉ៅការជាបុគ្គលដែលត្រូវទទួលខុសត្រូវលើព្យសនកម្ម។

ទី២ យោងតាមល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូលចំពោះការទទួលខុសត្រូវរបស់និយោជក យើងសង្កេតឃើញថា អ្នកម៉ៅការ ចាត់ទុកថាជានិយោជក ចំណែកឯនិយោជិក ជាកូនជាង ឬបុគ្គលផ្សេងទៀតដែលស្ថិតនៅក្រោមឱវាទរបស់អ្នកម៉ៅការ។ បុគ្គលដែលបានប្រើបុគ្គលណាម្នាក់ឲ្យធ្វើការងារអ្វីមួយ ដើម្បីប្រយោជន៍ខ្លួនត្រូវតែទទួលខុសត្រូវរាល់អំពើរបស់បុគ្គលនោះ ដូចគ្នាដែរ ករណីដែលអ្នកម៉ៅការ ប្រើនិយោជិករបស់ខ្លួន ដែលជាកូនជាងដើម្បីអនុវត្តកិច្ចការសម្រាប់ខ្លួនតាមការ

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៦៥២។

បង្គាប់ខ្លួន ក៏ត្រូវទទួលខុសត្រូវចំពោះអំពើរបស់កូនជាងដែរ ។ ដូចនេះ ក្នុងករណីដែលអ្នកម៉ៅការបំពេញការងារលើសំណង់ជាប់នឹងដីដោយមានវិការៈ ឬក្នុងពេលបំពេញការងារបណ្ដាលឲ្យមានព្យសនកម្មកើតឡើងលើសំណង់ ទ្រព្យសម្បត្តិផ្សេងៗ ឬលើរូបកាយរបស់តតិយជនណាម្នាក់ ដោយកំហុសរបស់អ្នកម៉ៅការផ្ទាល់ ដោយការគ្រប់គ្រងរបស់អ្នកម៉ៅការលើកូនជាងរបស់ខ្លួន ឬដោយការបំពេញការងាររបស់កូនជាងតាមការបង្គាប់របស់អ្នកម៉ៅការ ការត្រូវទទួលខុសត្រូវជាបន្ទុករបស់អ្នកម៉ៅការដែលត្រូវទទួលខុសត្រូវ។ ប៉ុន្តែប្រសិនបើព្យសនកម្មកើតឡើងដោយកំហុសរបស់កូនជាងខ្លួនផ្ទាល់ដោយមិនមានការបង្គាប់ ឬបញ្ជាពីអ្នកម៉ៅការ អ្នកម៉ៅការមិនមានកំហុសលើការគ្រប់គ្រងរបស់ខ្លួននោះទេ ដែលនាំឲ្យអ្នកម៉ៅការអាចរួចផុតពីការទទួលខុសត្រូវនេះបាន។

### ខ. កូនជាង

កូនជាង ជាជនដែលធ្វើការនៅក្រោមបង្គាប់ ឬការត្រួតត្រាពីមេជាង អ្នកម៉ៅការ ឬក្រុមហ៊ុនសំណង់។ ក្នុងករណីដែលកូនជាងធ្វើការងារដោយមិនយកចិត្តទុកដាក់ ឬធ្វេសប្រហែស ឬមិនធ្វើតាមការណែនាំ ឬការគ្រប់គ្រងរបស់មេជាង អ្នកម៉ៅការ ក្រុមហ៊ុនសំណង់ដែលជានិយោជក ប្រសិនបើបណ្ដាលឲ្យមានព្យសនកម្មណាមួយកើតឡើង កូនជាងត្រូវតែជាអ្នកទទួលខុសត្រូវដោយផ្ដោតទៅលើលក្ខខណ្ឌសំខាន់ៗនៃអំពើអនីត្យានុកូល ដូចជា អំពើបំពានសិទ្ធិ ឬប្រយោជន៍ ភាពខុសច្បាប់ កំហុស ការខូចខាត និងទំនាក់ទំនងហេតុផល យោងតាមមាត្រា៧៤៣ នៃក្រមរដ្ឋប្បវេណី។

### គ. តតិយជន

ក្រៅពីអ្នកម៉ៅការសំណង់ និងកូនជាង អាចមានតតិយជនផ្សេងទៀតដែលជួនកាលបានបង្កឲ្យមានអំពើអនីត្យានុកូលកើតឡើងក្នុងអំឡុងពេលសាងសង់សំណង់។ តតិយជន សំដៅលើជនទីបី ឬជនដែលមិនមែនជាភាគីនៅក្នុងទំនាក់ទំនងគតិយុត្ត[18]។ អាចមានករណីមួយចំនួនដែលមានអំពើអនីត្យានុកូលកើតឡើងបណ្ដាលឲ្យមានព្យសនកម្ម ដោយបុគ្គលដែលបង្កមិនមែនជាបុគ្គលដែលមានទំនាក់នៅក្នុងការសាងសង់សំណង់រួមមាន កម្មសិទ្ធិករ អ្នកម៉ៅការ កូនជាងជាដើម ប៉ុន្តែករណីបែបនេះមានតិចតួចណាស់ដែលបណ្ដាលមកពីតតិយជន។ ចំពោះការទទួលខុសត្រូវរបស់តតិយជន ដោយផ្អែកទៅលើល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូលដូចជា កំហុស អំពើបំពាន ភាពខុស

[18] សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លេខ៥៨, ទំព័រ ៦។

ច្បាប់ ការខូចខាត និងទំនាក់ទំនងរវាងអំពើបំពាន និងការខូចខាត ដែលបង្កឡើងដោយតតិយជន នៃមាត្រា ៧៤៣នេះដដែល។

### ២.១.២.២ ករណីជានីតិបុគ្គល

នីតិបុគ្គល ជាបណ្តុំក្រុមមនុស្ស ឬមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច[19]។ នីតិបុគ្គលមាន ២ប្រភេទគឺនីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ ដែលនីតិបុគ្គលទាំង ២ប្រភេទមានការទទួលខុសត្រូវដូចរូបវន្តបុគ្គលដែរចំពោះអំពើអនីត្យានុកូលលើសំណង់ជាប់នឹងដី ប៉ុន្តែស្ថិតក្នុងលក្ខខណ្ឌ និងការកំណត់ខុសពីគ្នា។

### ក. នីតិបុគ្គលឯកជន

នីតិបុគ្គលឯកជន ជាបណ្តុំក្រុមដែលបង្កើតឡើងក្នុងគោលដៅសម្រាប់ផលប្រយោជន៍ឯកជន ជាអាទិ៍ក្រុមហ៊ុន សមាគមន៍ សហជីព បណ្តុំក្រុមផលប្រយោជន៍សេដ្ឋកិច្ច។ សម្រាប់នីតិបុគ្គលឯកជនដែលពាក់ព័ន្ធការទទួលខុសត្រូវសំណង់ជាប់នឹងដីនេះចែកចេញជាពីរ គឺក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនធានារ៉ាប់រង។

### ក.១. ក្រុមហ៊ុនសាងសង់

ម្ចាស់ផ្ទះល្វែង ឬម្ចាស់អាគារ ឬម្ចាស់គម្រោងធំៗ ជាដើម តែងមានទំនុកចិត្តទៅលើក្រុមហ៊ុនសាងសង់ផ្សេងៗក្នុងការសាងសង់រាល់សំណង់ អគារខ្ពស់ៗ ផ្ទះល្វែងជាដើម។ល។ រវាងក្រុមហ៊ុនសាងសង់ និងម្ចាស់សំណង់ស្ទើរតែទាំងអស់តែងតែមានការចុះកិច្ចព្រមព្រៀង ឬបានចុះកិច្ចសន្យាសាងសង់ជាមួយគ្នាដើម្បីធ្វើការកំណត់នូវកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក ដូចនេះក្នុងករណីដែលក្នុងអំឡុងពេលសាងសង់ ព្យសនកម្មណាមួយកើតឡើងដោយសារបច្ចេកទេសក្នុងការសាងសង់ ការមិនបានប្រុងប្រយ័ត្ន ការគ្រប់គ្រងសំណង់មិនបានល្អរបស់ក្រុមហ៊ុនសំណង់ ឬបណ្តាលមកពីការបំពេញការងាររបស់បុគ្គលិកដែលធ្វើការឲ្យក្រុមហ៊ុនសាងសង់ ក្រុមហ៊ុនសាងសង់ ជានីតិបុគ្គលដែលមានកាតព្វកិច្ចទទួលខុសត្រូវលើការខូចខាតដោយផ្អែកលើកិច្ចសន្យាសាងសង់ ឬកិច្ចព្រមព្រៀងសាងសង់។

[19] សន្ធានុក្រមនៃក្រមរដ្ឋប្បវេណី លេខ៧១, ទំព័រ ១០។

## ក.២. ក្រុមហ៊ុនធានារ៉ាប់រង ឬគ្រឹះស្ថានធានារ៉ាប់រង

ក្រុមហ៊ុនធានារ៉ាប់រង សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងក្រុមហ៊ុនធានារ៉ាប់រងបន្ត។ ការធានារ៉ាប់រង គឺជាកិច្ចសន្យាមួយដែលធ្វើឡើងរវាងភាគីពីរ គឺរវាងធានាការី (ជាទូទៅគឺជាក្រុមហ៊ុនធានារ៉ាប់រង) និងអ្នកកាន់ប័ណ្ណធានារ៉ាប់រង (អ្នកដែលត្រូវបានធានារ៉ាប់រង) ដែលក្នុងនោះអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ឲ្យក្រុមហ៊ុនធានារ៉ាប់រងនូវទឹកប្រាក់មួយចំនួននូវទឹកប្រាក់មួយចំនួនដែលឲ្យឈ្មោះថា "បុព្វលាភធានារ៉ាប់រង" ។ ចំណែកឯក្រុមហ៊ុនធានារ៉ាប់រងវិញត្រូវធ្វើសំណងដល់អ្នកត្រូវបានធានារ៉ាប់រងវិញនូវផលប្រយោជន៍ ឬទឹកប្រាក់មួយចំនួនសម្រាប់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឬក៏ធ្វើសំណងនៅពេលដែលអ្នកធានារ៉ាប់រងស្លាប់ របួស ពិការ មានជម្ងឺ ឬនៅពេលដែលភាគីទាំងសងខាងបានឈានដល់ការកំណត់នៃការព្រមព្រៀងមួយ[20]។

ការធានារ៉ាប់រងត្រូវបានចែកចេញជាពីរប្រភេទធំៗ គឺការធានារ៉ាប់រងទូទៅ និងការធានារ៉ាប់រងបុគ្គល។ ចំពោះការធានារ៉ាប់រងទូទៅមាន ការធានារ៉ាប់រងលើទ្រព្យសម្បត្តិ និងការធានារ៉ាប់រងកាតព្វកិច្ច។ រីឯការធានារ៉ាប់រងបុគ្គលមាន ការធានារ៉ាប់រងលើគ្រោះថ្នាក់រាងកាយ និងការធានារ៉ាប់រងសុខភាពជាដើម។ ការធានារ៉ាប់រងពាក់ព័ន្ធនឹងការទទួលខុសត្រូវសំណង់ជាប់នឹងដីស្ថិតនៅក្នុងប្រភេទការធានារ៉ាប់រងទូទៅ។

ការធានារ៉ាប់រងទូទៅ ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងដែលក្នុងនោះ ការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាហានិភ័យលើទ្រព្យសម្បត្តិ ភារៈទទួលខុសត្រូវ និងសុខភាព។ ប្រភេទផលិតផលធានារ៉ាប់រងទូទៅរួមមាន ការធានារ៉ាប់រងទ្រព្យសម្បត្តិ ការធានារ៉ាប់រងភារៈទទួលខុសត្រូវ និងការធានារ៉ាប់រងសុខភាព។[21] ការទទួលខុសត្រូវលើអំពើអនីត្យានុកូលករណីសំណង់ជាប់នឹងដីពាក់ព័ន្ធនឹងការធានារ៉ាប់រងភារៈទទួលខុសត្រូវស្ថិតក្នុងការធានារ៉ាប់រងការដ្ឋាន។

[20] ច្បាប់ស្តីពីធានារ៉ាប់រង, នស/រកម/០៨១៤/០២១, កក្កដា ២០១៤, មាត្រា ៤។

[21] ច្បាប់ស្តីពីធានារ៉ាប់រង, នស/រកម/០៨១៤/០២១, កក្កដា ២០១៤, មាត្រា២៣។

ការធានារ៉ាប់រងការដ្ឋាននេះ ជាការទទួលខុសត្រូវដោយផ្ទាល់របស់ម្ចាស់ការដ្ឋាន ឬរបស់អ្នកម៉ៅការដែលខ្លួនបានធ្វើសកម្មភាពសាងសង់ រុះរើ និងវាយកម្ទេច ដែលសុទ្ធតែអាចបង្កអោយមានគ្រោះថ្នាក់ដល់អ្នករស់នៅជុំវិញការដ្ឋាន ឬអ្នកធ្វើដំណើរឆ្លងកាត់ និងអ្នកដែលរស់នៅក្បែរការដ្ឋាននោះ។ ហើយគ្រោះថ្នាក់នេះអាចជាការគ្រោះថ្នាក់ដែលធ្វើឲ្យប៉ះពាល់ដល់រូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ដោយម្ចាស់ការដ្ឋាន ឬអ្នកម៉ៅការចាំបាច់ត្រូវតែទទួលខុសត្រូវដោយសងសំណងទៅកាន់ជនរងគ្រោះ ដែលបានបង្កឡើងដោយអំពើអនីត្យានុកូលតាមរយៈក្រុមហ៊ុនធានារ៉ាប់រង។ ចំពោះម្ចាស់ការដ្ឋាន ឬអ្នកម៉ៅការដែលជារូបវន្តបុគ្គល ឬ ក្រុមហ៊ុនសាងសង់ ឬនីតិបុគ្គលផ្សេងៗវិញចាំបាច់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង នៅពេលដែលខ្លួនបើកការដ្ឋាន តែលើកលែងក្នុងករណីនីតិបុគ្គលសារធារណៈដែលទទួលបន្ទុកសាងសង់ ជួសជុល ឬតម្លើង ដើម្បីជាប្រយោជន៍សាធារណៈអាចត្រូវបានយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយអះអាងថា អាចមានលទ្ធភាពជួសជុលបានឆាប់រហ័ស និងគ្រប់គ្រាន់នូវការខូចខាតនោះ។

លើសពីនេះទៅទៀត ប្រភេទការដ្ឋានដែលចាំបាច់ត្រូវទិញធានារ៉ាប់រងនោះគឺ ការដ្ឋានដែលធ្វើការសាងសង់ តម្លើង និងជួសជុលគ្រប់ប្រភេទ ប៉ុន្តែប្រសិនបើគ្រាន់តែជាការសាងសង់ ឬជួសជុលកែលម្អតូចតាច គឺមិនចាំបាច់ទិញធានារ៉ាប់រងឡើយ។ ម្យ៉ាងទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុមានសិទ្ធិធ្វើការលើកលែងដល់ការដ្ឋានណាមួយ ដោយមិនចាំបាច់អនុវត្តធ្វើធានារ៉ាប់រងឡើយ ប្រសិនបើម្ចាស់ការដ្ឋាន ឬអ្នកម៉ៅការអះអាងបញ្ជាក់ថាខ្លួនមានលទ្ធភាពសងសំណងទាន់ពេលវេលា និងគ្រប់គ្រាន់ចំពោះការខូចខាតនានាដែលអាចកើតមានឡើង។

សរុបជារួមមកប្រសិនបើកម្មសិទ្ធិករ ម្ចាស់ការដ្ឋាន ក្រុមហ៊ុនសាងសង់ ឬអ្នកម៉ៅការបានទិញធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់ពាក់ពន្ធ័ការធានារ៉ាប់ការដ្ឋាន នៅពេលដែលមានការខូចខាតកើតឡើង ក្រុមហ៊ុនធានារ៉ាប់រងជានីតិបុគ្គលដែលត្រូវទទួលខុសត្រូវ។

**ខ. នីតិបុគ្គលសាធារណៈ**

នីតិបុគ្គលសាធារណៈ គឺជានីតិបុគ្គលដែលមានគោលដៅបម្រើផលប្រយោជន៍ទូទៅរួមមានរដ្ឋ សម្ព័ហភាពដែនដី និងបណ្តាគ្រឹះស្ថានសាធារណៈដទៃទៀត។ នីតិបុគ្គលសាធារណៈអាចជាក្រុមហ៊ុនរបស់រដ្ឋដែលធ្វើសកម្មភាពក្នុងការសាងសង់សំណង់ផ្សេងៗដូចជា អាគារស្ថាប័នរដ្ឋ ផ្លូវ

ផ្ទាល់ ស្ថានជាដើម។ ការអនុវត្តកាតព្វកិច្ចនៅក្នុងការទទួលខុសត្រូវនៅក្នុងករណីនេះមានលក្ខណៈប្រហាក់ប្រហែលនឹងនីតិបុគ្គលដែរ ដោយខុសគ្នាត្រង់ថាក្នុងករណីនេះជាស្ថាប័នសាធារណៈរបស់រដ្ឋ ឬរដ្ឋផ្ទាល់ដែលត្រូវទទួលខុសត្រូវលើសំណងការខូចខាតចំពោះអំពើបំពានដែលប្រព្រឹត្តឡើងដោយមន្ត្រីរាជការ ប៉ុន្តែត្រូវប្រាកដថាព្យសនកម្មនោះត្រូវតែប្រព្រឹត្តឡើងដោយមន្ត្រីរាជការ និងប្រព្រឹត្តក្នុងពេលបំពេញកិច្ចការងាររបស់រដ្ឋ ទើបជាទំនួលខុសត្រូវរបស់រដ្ឋទៅលើសំណងព្យសនកម្មនោះបាន។ មន្ត្រីរាជការត្រូវរាប់បញ្ចូលទាំងអស់នូវមន្ត្រីស៊ីវិល មន្ត្រីយោធា និងមន្ត្រីរាជរដ្ឋាភិបាលដែលទទួលបានការអនុវត្តអំណាចសាធារណៈរបស់រដ្ឋ ឬស្ថាប័នសាធារណៈបានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន។ ប្រសិនបើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការមានភាពធ្ងន់ធ្ងរពេក រដ្ឋក៏អាចធ្វើការទាមទារនូវសំណងព្យសនកម្មពីមន្ត្រីរាជការវិញបានដែរ ដោយផ្អែកលើគោលការណ៍កំហុសរបស់មន្ត្រីរាជការដែលបានប្រព្រឹត្តបំពាន[22]។

## ២.២ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលករណីសំណង់ជាប់នឹងដីក្រោយពេលសាងសង់

អំឡុងពេលក្រោយការសាងសង់ ជារយៈពេលដែលសំណង់បានសាងសង់រួចរាល់តាមការព្រមព្រៀងរបស់កម្មសិទ្ធិករ និងអ្នកម៉ៅការ ឬក្រុមហ៊ុនសាងសង់។ ក្រោយពេលសាងសង់សំណង់នេះដែរ មានករណីពីរដែលត្រូវយកមកពិចារណាទៅលើការទទួលខុសត្រូវ ករណីទី១ ប្រសិនបើសំណង់រួចរាល់ហើយប៉ុន្តែមិនទាន់បានប្រគល់ទៅឲ្យកម្មសិទ្ធិករ ករណីទី២ ប្រសិនបើសំណង់ប្រគល់ទៅឲ្យកម្មសិទ្ធិកររួចរាល់ មានន័យថាកម្មសិទ្ធិករបានគ្រប់គ្រងសំណង់របស់ខ្លួនរួចរាល់ នៅពេលដែលមានអំពើអនីត្យានុកូលកើតឡើង តើអ្នកទទួលខុសត្រូវ ជាកម្មសិទ្ធិករ ឬអ្នកម៉ៅការ ឬក្រុមហ៊ុនសាងសង់?

### ២.២.១ ភាគីដែលត្រូវទទួលខុសត្រូវលើព្យសនកម្ម

#### ២.២.១.១ ករណីមិនទាន់ប្រគល់សំណង់

អំឡុងពេលដែលសំណង់មិនទាន់ប្រគល់ទៅឲ្យកម្មសិទ្ធិករ សំណង់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកម៉ៅការ ឬក្រុមហ៊ុនសាងសង់នៅឡើយ ហើយក្នុងអំឡុងពេលនេះដែរ ការទទួល

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៩។

ខុសត្រូវ និងបុគ្គលដែលទទួលខុសត្រូវ មានលក្ខណៈដូចគ្នាដែរជាមួយនឹងការទទួលខុសត្រូវ និងបុគ្គលដែលទទួលខុសត្រូវក្នុងអំឡុងពេលសាងសង់ដែរ មានដូចជា អ្នកម៉ៅការ ឬក្រុមហ៊ុនសាងសង់ និងតតិយជន គ្រាន់តែមួយនៅក្នុងអំឡុងពេលសាងសង់សំណង់ មានន័យថាសំណង់មិនទាន់រួច និងអំឡុងពេលដែលសំណង់បានសាងសង់រួចរាល់តែមិនទាន់បានប្រគល់ទៅឲ្យកម្មសិទ្ធិករគ្រប់គ្រង ។

### ២.២.១.២ ករណីប្រគល់សំណង់រួចរាល់

### ក. កម្មសិទ្ធិករ ឬសហកម្មសិទ្ធិករ

#### ក.១ កម្មសិទ្ធិករ

កម្មសិទ្ធិ សំដៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាននៅក្នុងទំហំច្បាប់ដែលបានកម្រិត[23]។ កម្មសិទ្ធិដីត្រូវមានអានុភាពទាំងផ្នែកលើដី និងផ្នែកក្រោមដីនៅក្នុងទំហំនៃការកម្រិតដែលច្បាប់ និងបទដ្ឋានគតិយុត្តបានកំណត់ ហើយក្នុងទំហំដែលមានផលប្រយោជន៍សម្រាប់កម្មសិទ្ធិករ[24]។ រីឯកម្មសិទ្ធិករ គឺជាម្ចាស់សិទ្ធិដែលជាបុគ្គលឯកជន រួមមានរូបវន្តបុគ្គល និងនីតិបុគ្គលឯកជន ដែលជាម្ចាស់កម្មសិទ្ធិលើទ្រព្យ និងមានសិទ្ធិប្រើប្រាស់សិទ្ធិ អាស្រ័យផល និងមានសិទ្ធិចាត់ចែងលើទ្រព្យនានាដែលជារបស់ខ្លួនដោយសេរី និងផ្តាច់មុខ លើកលែងតែមានការហាមឃាត់ដោយច្បាប់ ឬដោយបទបញ្ញត្តិនានា មានន័យថា កម្មសិទ្ធិករអាចប្រើប្រាស់សិទ្ធិលើទ្រព្យរបស់ខ្លួនស្ថិតក្នុងទំហំដែលច្បាប់អនុញ្ញាតិ។ កម្មសិទ្ធិករនៃដីមិនអាចប្រើប្រាស់ដីរបស់ខ្លួនក្នុងគោលបំណងព្យាបាទអ្នកដទៃ ឬរំខានដល់ជីវភាពរស់នៅរបស់អ្នកដទៃតែប៉ុណ្ណោះបានឡើយ[25]។

នៅពេលដែលមានអំពើអនីត្យានុកូលកើតឡើងគេតែងស្វែងរកថា តើបុគ្គលណាម្នាក់ជាកម្មសិទ្ធិករ? ដើម្បីឲ្យបុគ្គលនោះទទួលខុសត្រូវលើសំណងការខូចខាតលើអំពើអនីត្យានុកូលនៃសំណង់ដែលបង្កឡើង។ ការទាមទារឲ្យកម្មសិទ្ធិករទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដីត្រូវផ្អែកទៅលើសិទ្ធិកម្មសិទ្ធិ និងការគ្រប់គ្រងសំណង់ ប្រសិនបើកម្មសិទ្ធិករនៃសំណង់ ជាអ្នក

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៣៨។

[24]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៣៩ កថាខណ្ឌទី១។

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៣៩ កថាខណ្ឌទី២។

គ្រប់គ្រងសំណង់ដោយខ្លួនឯង នោះការទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងបណ្តាលពីសំណង់ ជាបន្ទុករបស់កម្មសិទ្ធិករទាំងស្រុង។ ប្រសិនបើកម្មសិទ្ធិករនៃសំណង់បានជួលសំណង់ ឬប្រគល់ការគ្រប់គ្រងសំណង់ តាមលក្ខណៈផ្សេងៗឲ្យទៅអ្នកដទៃ នោះកម្មសិទ្ធិករ និងអ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវដោយសាមគ្គី។ កម្មសិទ្ធិករនៃសំណង់មិនអាចរួចផុតពីការទទួលខុសត្រូវបានទេ ប៉ុន្តែអាចទាមទារពីអ្នកគ្រប់គ្រងបាន ប្រសិនបើជាកំហុសរបស់អ្នកគ្រប់គ្រង។

### ក.២ សហកម្មសិទ្ធិករ

សហកម្មសិទ្ធិករ គឺជាស្ថានភាពដែលកម្មសិទ្ធិនៃអចលនទ្រព្យណាមួយត្រូវបានបែងចែករវាងបុគ្គលច្រើនគ្នាទៅតាមចំណែករបស់បុគ្គលម្នាក់ៗ។ សហកម្មសិទ្ធិករម្នាក់ៗមានសិទ្ធិកម្មសិទ្ធិដាច់ដោយឡែកពីគ្នាអាស្រ័យទៅតាមចំណែករបស់បុគ្គលឯកជនរៀងៗខ្លួន ក្នុងការអាស្រ័យផលប្រើប្រាស់សិទ្ធិទៅតាមការកំណត់ និងមានសិទ្ធិចាត់ចែង ហើយបុគ្គលទាំងនោះក៏មាននូវសិទ្ធិអវិភាគទៅលើចំណែក ឬផ្នែកសម្ហភាពក្នុងការប្រើប្រាស់អាស្រ័យផលដោយគោរពទៅតាមការកំណត់របស់កម្មសិទ្ធិដោយមិនមានប៉ះពាល់ទៅដល់ប្រយោជន៍របស់អ្នកដទៃទៀត។ ចំពោះសហកម្មសិទ្ធិករត្រូវមានភារកិច្ចទៅលើការថែទាំ ជួសជុលដែលជាបន្ទុករបស់សហកម្មសិទ្ធិករគ្រប់ៗរូបដោយមានការបែងចែកនូវចំណែកនៃការចូលរួមនោះដោយស្មើភាពគ្នាទៅលើបុគ្គលរៀងៗខ្លួន[26]។ ហេតុដូចនេះហើយ នៅពេលដែលមានការខូចខាតណាមួយកើតមានឡើងដោយស្ថិតនៅក្នុងបន្ទុករួមរបស់សហកម្មសិទ្ធិករ នោះសហកម្មសិទ្ធិករត្រូវទទួលខុសត្រូវទៅលើទំហំនៃការខូចខាតនោះរួមគ្នា ដែលមានការបែងចែកចំណែករៀងៗខ្លួនក្នុងការសងសំណងទទួលខុសត្រូវទៅលើជនរងគ្រោះដែលទទួលបាននូវព្យសនកម្មនោះ។

- **កម្មសិទ្ធិអវិភាគ** គឺជាស្ថានភាពដែលបុគ្គលច្រើននាក់ មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ (មាត្រា ២០២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា)។

[26] ស្រី វណ្ណធី, នីតិរដ្ឋប្បវេណី (២០១៦), ៣៧-៤៥។

### ខ. អ្នកគ្រប់គ្រងសំណង់

អ្នកគ្រប់គ្រងសំណង់ គឺជាអ្នកកាន់កាប់ ថែរក្សា ភតិក:ដែលដែលជាបុគ្គលដែលទទួលបានសិទ្ធិប្រើប្រាស់ អាស្រ័យផលពីសំណង់របស់ភតិបតី។ ស្ថិតនៅក្នុងអំឡុងពេលដែលសំណង់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកគ្រប់គ្រង ប្រសិនបើសំណង់បានបង្កឲ្យមានការខូចខាតអ្នកគ្រប់គ្រងសំណង់ និងកម្មសិទ្ធិករនៃសំណង់ត្រូវទទួលទទួលខុសត្រូវដោយសាមគ្គី ហើយអ្នកគ្រប់គ្រងសំណង់ និងកម្មសិទ្ធិករនៃសំណង់ទទួលខុសត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឲ្យមានវិការ:[27]។ បើសិនជាអ្នកគ្រប់គ្រងសំណង់អាចអះអាង ឬបានបញ្ជាក់ភស្តុតាង អំពីការគ្រប់គ្រងថាខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវដើម្បីរួចផុតពីការទទួលខុសត្រូវបាន។ ដោយឡែកចំពោះម្ចាស់កម្មសិទ្ធិវិញ ពុំមានបញ្ញត្តិណាមួយឲ្យលើកលែងដូចនេះទេ។

### គ. ក្រុមហ៊ុនសាងសង់ ឬអ្នកម៉ៅការ

ដូចដែរបានបកស្រាយនៅក្នុងចំណុចនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនសាងសង់ និងអ្នកម៉ៅការក្នុងអំឡុងពេលសាងសង់រួចមកហើយក្រុមហ៊ុនសាងសង់ និងអ្នកម៉ៅការ មានករណីយកិច្ចសម្រេចការងារដោយគ្មានវិការ:ចំពោះម្ចាស់ការ ដែលជាកម្មសិទ្ធិករ ដូចនេះក្នុងករណីសំណង់បានប្រគល់ទៅឲ្យកម្មសិទ្ធិកររួចរាល់ សំណង់បានបង្កឲ្យមានការខូចខាតដោយសារតែការសាង់សង់ដូចជា បច្ចេកទេសនៃការសាងសង់ ការសាងសង់មិនបានត្រឹមត្រូវដោយមានការធ្វេសប្រហែសជាដើម ក្រុមហ៊ុនសាងសង់ និងអ្នកម៉ៅការមានកាតព្វកិច្ចត្រូវជួសជុលព្យសនកម្មដែលកើតមាន។ ប៉ុន្តែការទាមទារឲ្យក្រុមហ៊ុនសាងសង់ និងអ្នកម៉ៅការទទួលខុសត្រូវលើសំណងព្យសនកម្មលើអំពើអនីត្យានុកូលចំពោះសំណង់ពិតមែន កម្មសិទ្ធិករនៃសំណង់មិនអាចទាមទារឲ្យក្រុមហ៊ុនសាងសង់ និងអ្នកម៉ៅការដែលជាអ្នកស្ថាបនាឲ្យទទួលខុសត្រូវដោយផ្អែកលើអំពើអនីត្យានុកូលបានទេ ប៉ុន្តែអាចទាមទារឲ្យសងចំពោះសំណងដែលខ្លួនបានសងទៅជនរងគ្រោះបានតាមរយ:កិច្ចសន្យាម៉ៅការ និងកិច្ចសន្យាសាងសង់។

លើសពីនេះទៅទៀត ក្រៅពីកម្មសិទ្ធិករ អ្នកគ្រប់គ្រងសំណង់ អ្នកម៉ៅការ ក្រុមហ៊ុនសាងសង់ ករណីខ្លះដូចដែរបានរៀបរាប់នៅក្នុងអំឡុងពេលសាងសង់ដែរ មានតតិយជនផ្សេងទៀតដែល

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៥៣ កថាខណ្ឌទី២

អាចបង្កឲ្យមានព្យសនកម្មលើសំណង់ជាប់នឹងដីដែរទាំងក្នុងអំឡុងពេលសាងសង់នឹងក្រោយពេលសាងសង់ ដែលត្រូវជាបុគ្គលដែលត្រូវទទួលខុសត្រូវលើព្យសនកម្ម។

ចំណែកឯការទូទាត់សំណង និងការទាមទារសំណង លើអំពើអនីត្យានុកូលសំណង់ជាប់នឹងដីយើងខ្ញុំសូមមិនលើកយកមកបកស្រាយ ដោយហេតុថាគោលបំណងនៃសារណានេះផ្ដោតសំខាន់ទៅលើការទទួលខុសត្រូវ រីឯការទូទាត់សំណង និងការទាមទារសំណងស្ថិតនៅក្នុងនីតិវិធីរបស់តុលាការ។

## ២.៣ លក្ខខណ្ឌនៃការទទួលខុសត្រូវករណីសំណង់ជាប់នឹងដី

ការទទួលខុសត្រូវទៅលើព្យសនកម្មដែលកើតមកពីសំណង់ជាប់នឹងដីនេះ អាចអនុវត្តទៅបានដោយលុះត្រាតែកម្មវត្ថុនៃព្យសនកម្មនោះកើតឡើងដោយសារតែសំណង់ពិតប្រាកដ ឬមូលហេតុដែលបង្កកើតឡើងដោយសារតែផ្នែកណាមួយនៃសំណង់ពិតមែនដោយការធ្វេសប្រហែស ឬកង្វះការថែទាំ ឬដោយមានវិការៈណាមួយកើតមានឡើង។ លក្ខខណ្ឌដែលត្រូវទទួលខុសត្រូវនូវករណីដូចជា ករណីបាក់ស្រុត ឬដួលរលំសំណង់ ឬអាគារ ករណីអគ្គីភ័យ និងករណីខូចខាត ឬប៉ះពាល់ទៅដល់អ្នកដទៃ ជាដើម ។

### ២.៣.១ ករណីការបាក់ស្រុត ឬដួលរលំសំណង់ ឬអាគារ

ការទទួលខុសត្រូវក្នុងករណីនេះ គឺតម្រូវឲ្យអាគារ ឬសំណង់មួយបានបង្កឲ្យមានព្យសនកម្មដោយសារតែអំពើនៃការដួលរលំនៃផ្នែកណាមួយនៃអាគារ ឬសំណង់ ឬដោយសារតែអាគារឬសំណង់នោះទាំងស្រុងផ្អែកទៅលើវិការៈនៃសំណង់ ឬការធ្វេសប្រហែសណាមួយនៃការសាងសង់ដែលមាននូវភស្តុតាងជាក់ស្តែងនៅក្នុងការដាក់បន្ទុកថាសំណង់ ឬអាគារនោះពិតជាដើមហេតុនៃការខូចខាតនោះពិតប្រាកដ ។ ហេតុនេះកម្មសិទ្ធិករត្រូវតែទទួលខុសត្រូវទៅលើការខូចខាតដែលបានបង្កទៅដល់ជនរងគ្រោះទាំងស្រុងដោយមិនអាចប្រកែកបាន ហើយជនរងគ្រោះក៏អាចទាមទារនូវសំណងនៃការខូចខាតពីកម្មសិទ្ធិករវិញបានដែរ។

#### ២.៣.១.១ វិការៈនៃការសាងសង់

វិការៈនៃការសាងសង់ មានន័យថាការកើតមានឡើងនូវភាពមិនប្រក្រតីនៅត្រង់ចំណុចណាមួយនៃការសាងសង់ដែលនាំឲ្យសំណង់ ឬអាគារមានការដួលរលំ ឬបាក់ស្រុតដែលកើតឡើងដោយសារតែការសាងសង់សំណង់របស់ស្ថាបត្យករ ឬសហគ្រិនសាងសង់នៃអាគារនោះមិនស្រប

ទៅតាមបច្ចេកទេសនៃការសាងសង់ ឬបញ្ហាបច្ចេកទេស ឬបញ្ហាគុណភាពដែលបង្កឲ្យមានការខូចខាតនេះកើតមានឡើង។ ប៉ុន្តែកម្មសិទ្ធិករក៏នៅតែទទួលខុសត្រូវទៅលើការខូចខាតទៅកាន់ជនរងគ្រោះដែរ ព្រោះថាជាកាតព្វកិច្ចនៃការទទួលខុសត្រូវរបស់កម្មសិទ្ធិករ ក្រោយពីទទួលខុសត្រូវលើជនរងគ្រោះហើយកម្មសិទ្ធិករមានសិទ្ធិនៅក្នុងការទាមទារនូវសំណងការខូចខាតនោះពីស្ថាបត្យករ ឬសហគ្រិនសាងសង់នោះមកវិញបានដោយសារតែវាមានកំហុសខាងវិការៈនៃការសាងសង់ មិនមែនជាកំហុសដែលកើតឡើងដោយសារតែកម្មសិទ្ធិករឡើយ[28]។

**២.៣.១.២ ការធ្វេសប្រហែសនៃការសាងសង់**

ករណីនៃការធ្វេសប្រហែសនេះក៏មិនខុសគ្នាពីវិការៈនៃការសាងសង់នេះដែរ ដោយហេតុថាការខូចខាតត្រូវបានបង្កឡើងដោយសារតែការធ្វេសប្រហែសរបស់ស្ថាបត្យករ ឬសហគ្រិនក្នុងការសាងសង់ទៅលើសំណង់ ឬអាគារដែលនាំឲ្យមានការដួលរលំ ឬបាក់ស្រុតកើតឡើងដោយហេតុមិនបានបំពេញតួនាទីឲ្យបានពេញលេញ មិនយកចិត្តទុកដាក់ ឬមានការធ្វេសប្រហែស ឬខ្ជីខ្ជាទៅលើការសាងសង់របស់ខ្លួន ដែលតម្រូវឲ្យស្ថាបត្យករ ឬសហគ្រិននៃសំណង់នោះសងសំណងខូចខាតទៅកាន់កម្មសិទ្ធិករ ហើយកម្មសិទ្ធិករត្រូវបន្តសងនូវការខូចខាតនោះទៅឲ្យជនរងគ្រោះវិញផងដែរ។

**២.៣.២ ករណីអគ្គីភ័យ**

ការទទួលខុសត្រូវនៅក្នុងករណីអគ្គីភ័យនេះតម្រូវឲ្យដើមហេតុដែលបង្កឲ្យមានការខូចខាតនោះកើតចេញពីផ្នែកណាមួយនៃសំណង់ ឬអាគារដោយមានភស្តុតាងនៅក្នុងការលើកយកមកបញ្ជាក់ថាវាពិតជាបានកើតឡើងដោយសារតែអគ្គីភ័យនៃសំណង់ ឬអាគារនោះជាប្រភពនៃភ្លើងដែលបណ្តាលឲ្យរីករាលដាលទៅដល់អ្នកដទៃ ឬជាប្រភពនៃភ្លើងដែលបានឆេះរាលដាលទៅដល់លំនៅដ្ឋានរបស់អ្នកជិតខាងដែលបានបង្កឡើងដោយម្ចាស់សំណង់ ឬម្ចាស់អាគារនោះ[29]។

**២.៣.២.១ សំណង់ដែលមានម្ចាស់គ្រប់គ្រងថែរក្សា**

ម្ចាស់ដែលគ្រប់គ្រងថែរក្សាសំណង់ ឬអាគារនោះត្រូវតែទទួលខុសត្រូវទៅលើការខូចខាតដែលខ្លួនបានបង្កឡើងទៅដល់ជនរងគ្រោះក្នុងករណីអគ្គីភ័យ ដែលបានប៉ះពាល់ទៅដល់អ្នកដទៃ

[28] ដូច ៥, ៣៩។

[29] ដូច ៥, ៤០។

ដោយសារតែការធ្វេសប្រហែស ឬមិនយកចិត្តទុកដាក់ដែលបានបង្កឲ្យកើតមានឡើងនូវប្រភពភ្លើងរហូតបណ្តាលឲ្យរីករាលដាលទៅដល់លំនៅដ្ឋានរបស់អ្នកដទៃទៀត។ ហេតុនេះម្ចាស់កម្មសិទ្ធិត្រូវផ្តល់សំណងលើព្យសនកម្មទៅដល់ជនរងគ្រោះទៅតាមទំហំនៃការខូចខាតដែលកើតចេញពីកំហុសរបស់ខ្លួនយ៉ាងពេញទី។

### ២.៣.២.២ ប្រភពនៃអគ្គីភ័យ

ដូចដែលបានបញ្ជាក់ពីខាងលើទាក់ទងទៅនឹងករណីអគ្គីភ័យ ដែលតម្រូវឲ្យមានការទទួលខុសត្រូវ គឺសំណង់ ឬអាគារនោះជាប្រភពនៃអគ្គីភ័យដែលមានន័យថាអាគារ ឬសំណង់នោះជាមូលហេតុដែលនាំឲ្យមានកើតចេញនូវអគ្គីភ័យពីការមិនប្រុងប្រយ័ត្ន ឬខ្វះការមើលថៃ ឬយកចិត្តទុកដាក់ពីសំណាក់ម្ចាស់កម្មសិទ្ធិ ដែលបានបង្កឲ្យមានភ្លើងកើតមានឡើងដែលនាំឲ្យឆេះរាលរហូតមានការប៉ះពាល់ទៅលើអ្នកដទៃទៀត។ ដូចនេះម្ចាស់កម្មសិទ្ធិក៏ត្រូវតែធ្វើការជួសជុល និងសងទៅលើការខូចខាតដែលខ្លួនបានប្រព្រឹត្តទៅឲ្យជនរងគ្រោះជាដាច់ខាតទៅតាមទំហំខូចខាតជាក់ស្តែង។

### ២.៣.៣ ករណីការខូចខាត ឬប៉ះពាល់ដល់អ្នកដទៃ

ករណីដែលបង្កឲ្យមានការខូចខាត ឬប៉ះពាល់ដល់អ្នកដទៃនេះ គឺជាលក្ខខណ្ឌមួយដែលមូលហេតុនៃការខូចខាតកើតមានឡើងក្រៅពីករណីដួលរលំ ឬបាក់ស្រុតអាគារ និងករណីអគ្គីភ័យទាំងពីរនេះ។ ដែលតម្រូវឲ្យមានការសងនូវព្យសនកម្មដោយសារតែអំពើប្រព្រឹត្តរបស់ជនបង្កទៅលើសកម្មភាព ឬទង្វើណាមួយដែលបានបង្កនូវឲ្យមាននូវផលប៉ះពាល់ទៅដល់ជនរងគ្រោះមិនថាជាការខូចខាតទៅលើផ្នែករូបរាងកាយ ផ្នែកសតិអារម្មណ៍ ឬទ្រព្យសម្បត្តិនោះទេ ក៏វាជាបន្ទុករបស់ជនបង្កនៅក្នុងការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនដដែល។

## ២.៤ ការរួចផុតពីការទទួលខុសត្រូវ

នៅពេលដែលមានអំពើអនីត្យានុកូលកើតឡើងបង្កឲ្យមានការខូចខាតដល់ជនរងគ្រោះ ឬកម្មសិទ្ធិករ ឬទ្រព្យសម្បត្តិពាក់ព័ន្ធនឹងសំណង់ផ្សេងៗ ជនរងគ្រោះ ឬកម្មសិទ្ធិករអាចទាមទារ ត្រឹមតែឲ្យជនដែលបង្កសងសំណងបាន ប៉ុន្តែមិនមែនសុទ្ធតែមានអំពើអនីត្យានុកូលពាក់ព័ន្ធនឹងសំណង់ជាប់នឹងដីកើតឡើងបុគ្គលដែលបង្កត្រូវតែទទួលខុសត្រូវនោះទេ បុគ្គលដែលបង្កអាចរួចផុតពីការទទួលខុសត្រូវបានដោយសារតែមូលហេតុដូចជា ការការពារជាធម្មានុរូប និងស្ថានភាពចាំបាច់

អសមត្ថភាពក្នុងការទទួលខុសត្រូវ កំហុសទាំងស្រុងរបស់ជនរងគ្រោះ និងការព្រមព្រៀងពីជនរងគ្រោះ និងករណីប្រធានសក្តិ។

## ២.៤.១ ការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់

ការការពារជាធម្មានុរូប គឺសំដៅទៅលើអំពើ រំលោភដែលពុំអាចជៀសវាងបានដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន ឬអំពើរំលោភសិទ្ធិស្ថិតជិតគ្នា និងមានតុល្យភាពរវាងវិធីការពារ និងកម្រិតនៃអំពើបំពាននោះ។ រីឯស្ថានភាពចាំបាច់ គឺសំដៅទៅលើអំពើរំលោភដែលមិនអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬអច្ចាសន្ន (គ្រោះថ្នាក់ដែលហៀបនឹងកើតឡើងយ៉ាងពិតប្រាកដ) ហើយដែលស្ថិតក្នុងករណីមានតុល្យភាពរវាងវិធីការពារ និង កម្រិតនៃគ្រោះថ្នាក់នោះ[30]។

យោងតាមស្មារតីនៃកថាខណ្ឌទី២ មាត្រា៧៥៦ នៃក្រមរដ្ឋប្បវេណីបានបញ្ជាក់ថា អំពើការពារជាធម្មានុរូប និងអំពើដោយសារស្ថានភាពចាំបាច់ដូចបានកំណត់ខាងលើបើបានបង្កឲ្យមានការខូចខាតនោះបុគ្គលដែលប្រព្រឹត្តមិនបាច់ទទួលខុសត្រូវនោះទេ។ បន្ថែមពីលើនេះទៀតមាត្រាដដែលក៏បានលើកឡើងពីការរួចផុតពីភាពផ្ទុយច្បាប់ផ្សេងទៀតដែលមានដូចជា ការយល់ព្រម ឬការទទួលយកគ្រោះថ្នាក់ពីសំណាក់អ្នករងគ្រោះដោយសមហេតុផល និងអំពើបង្កការខូចខាតដែលត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល។ ប៉ុន្តែអំពើដែលសង្គមទទួលថាសមហេតុផល និងអាចទទួលយកបាននោះ គឺមានលក្ខណៈពិបាកបញ្ជាក់ណាស់ ហើយបញ្ហានេះត្រូវអាស្រ័យទៅលើអត្ថន័យនៃយុត្តិធម៌។

## ២.៤.២.អសមត្ថភាពក្នុងការទទួលខុសត្រូវ

ទាក់ទងនឹងសមត្ថភាពនេះដែរ ជាគោលការណ៍ក្រមរដ្ឋប្បវេណី បានផ្តល់នូវការការពារជនដែលមានសមត្ថភាពទាប ហើយដែលមិនអាចវិនិច្ឆ័យ និងធ្វើសកម្មភាពតាមលក្ខណៈសមហេតុ

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៥៥។

ផល។ ការទទួលខុសត្រូវខាងអំពើអនីត្យានុកូល អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ឬជនដែលមានវិបត្តិផ្នែកស្មារតី គឺរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល[31]។

ដូចដែលមានបញ្ជាក់ត្រង់មាត្រា ៧៤៥ កថាខណ្ឌទី២ បុគ្គលដែលមានវិបត្តិផ្នែកស្មារតី គឺត្រូវរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល។ ប៉ុន្តែមិនដូចជាជនដែលស្ថិតនៅក្រោមអាយុ ១៤ ទេ ជនបែបនេះនៅតែត្រូវទទួលខុសត្រូវនៅក្នុងករណី ដែលជននេះអសមត្ថភាពដោយកំហុសចេតនា ឬ ដោយកំហុសអចេតនានោះ ។

### ២.៤.៣ កំហុសទាំងស្រុងរបស់ជនរងគ្រោះ និង ការព្រមព្រៀងពីជនរងគ្រោះ

បុគ្គលដែលធ្វើឲ្យមានការខូចខាតដល់អ្នកដទៃ អាចរួចផុតពីការទទួលខុសត្រូវ ឬមិនត្រូវទទួលខុសត្រូវ ប្រសិនបើការខូចខាតនោះបណ្តាលមកពីកំហុសរបស់ជនរងគ្រោះខ្លួនឯង មានន័យថា បុគ្គលដែលបង្កអំពើអនីត្យានុកូលសំណង់ជាប់នឹងដីមិនមានកំហុសក្នុងការបង្កឲ្យមានអំពើអនីត្យានុកូលកើតឡើងលើសំណង់ណាមួយនោះឡើយ តែវាជាការបង្កឡើងដោយសារតែកំហុសរបស់ជនរងគ្រោះ។

បុគ្គលដែលបានប្រព្រឹត្តអំពើអនីត្យានុកូលអាចរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការយល់ព្រម ឬ ការទទួល យកគ្រោះថ្នាក់ពីសំណាក់ជនរងគ្រោះ[32] ។ ដោយករណីនេះអាចជនរងគ្រោះមិនធ្វើការទាមទារសំណងទៅលើជនដែលបានបង្ក ឬមិនចាំបាច់ឲ្យជនដែលបង្កសងសំណងលើព្យសនកម្មមកឲ្យខ្លួនវិញដែរ។

### ២.៤.៤ ករណីប្រធានសក្តិ

ការខូចខាតបណ្តាលមកពីករណីប្រធានសក្តិ អ្នកប្រព្រឹត្តមិនត្រូវបានទទួលខុសត្រូវទេ ពីព្រោះករណីប្រធានសក្តិ ជាព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈរបស់ភាគី មិនអាចដឹងមុន ហើយមិនអាចជំនះបាន។ **ឧទាហរណ៍៖** ដូចជាករណីខ្យល់ព្យុះ ទឹកជំនន់...... ដែលបានបណ្តាលឲ្យសំណង់ទទួលរងនូវការខូចខាតដោយស្ថិតនៅក្នុងអំឡុងពេលសាងសង់ដូចជា មានការបាក់ ឬស្រុតផ្នែកណាមួយនៃសំណង់ ដែលជាករណីអាចឲ្យក្រុមហ៊ុនសំណង់ ឬអ្នកមៅការសំណង់រួចផុត

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៥ ។

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៥៦។

ពីការទទួលខុសត្រូវបាន ដោយសារតែការខូចខាតដែលបានកើតឡើងនេះមិនមែនកើតចេញពីកំហុសរបស់ក្រុមហ៊ុនសំណង់ ឬអ្នកម៉ៅការឡើយ តែវាបណ្តាលមកពីគ្រោះទឹកជំនន់ ឬខ្យល់ព្យុះដែលកើតឡើង។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបកស្រាយទៅលើប្រធានបទខាងលើរួចមក យើងសង្កេតឃើញថា ការទទួលខុសត្រូវលើអំពើអនីត្យានុកូល (ករណីសំណង់ជាប់នឹងដី) នេះមានលក្ខណៈស្របទៅតាមបរិបទនាពេលបច្ចុប្បន្នដែលជាបញ្ហាចំបងមួយសម្រាប់ប្រទេសកម្ពុជាយើង និងបណ្តាប្រទេសនានា។ ដោយសារតែសង្គមតម្រូវឲ្យមានការរីកចម្រើន និងអភិវឌ្ឍន៍ទាំងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យដទៃទៀតប្រកបដោយសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ព្រមទាំងទាមទារឲ្យមានការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ជាពិសេសនីតិរដ្ឋ តួយ៉ាងព្រះរាជាណាចក្រកម្ពុជាយើង ជាប្រទេសដែលប្រកាន់យកគោលការណ៍ច្បាប់ជាធំ ដែលពលរដ្ឋគ្រប់រូបត្រូវតែគោរពច្បាប់ដែលបានកំណត់ ហើយប្រសិនបើមានការប្រព្រឹត្តល្មើសច្បាប់ដោយចេតនាក្តី ឬអចេតនាក្តីត្រូវតែទទួលខុសត្រូវទៅលើព្យសនកម្មដែលខ្លួនបានបង្កឡើងជាដាច់ខាត។

ហេតុនេះ ការទទួលខុសត្រូវពិតជាមានសារៈសំខាន់ណាស់ចំពោះសង្គមជាតិ និងប្រជាពលរដ្ឋគ្រប់រូប។ ដូចនឹងអ្វីដែលបានរៀបរាប់ពីខាងដើមនៅពេលដែលមានការរីកចម្រើនកើតឡើងរមែងទាមទារឲ្យមានការកសាងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដើម្បីបំពេញតម្រូវការដល់ការរស់នៅ ការធ្វើអាជីវកម្ម ពាណិជ្ជកម្ម និងការកសាងនូវសំណង់ជាច្រើនដែលមានការរីកដុះដាលជាលំដាប់។ ទន្ទឹមនឹងនេះ អត្ថប្រយោជន៍ដែលបានមកពីសំណង់ និងព្យសនកម្មដែលកើតចេញពីសំណង់នេះ ក៏បានដើរទន្ទឹមគ្នាដែរ។ ដោយហេតុថាប្រជាពលរដ្ឋយើងមួយចំនួនពុំទាន់មានការយល់ដឹងទូលំទូលាយអំពីការទទួលខុសត្រូវលើសំណង់ជាប់នឹងដីនេះ ទើបធ្វើឲ្យគេគិតថានៅពេលដែលមានព្យសនកម្មកើតមានឡើងបង្កឲ្យមានការខូចខាតដោយសំណង់ជាប់នឹងដី បន្ទុកក្នុងការទទួលខុសត្រូវ គឺត្រូវធ្លាក់ទៅលើកម្មសិទ្ធិករដែលជាអ្នកទទួលខុសត្រូវជានិច្ច។ ការទទួលខុសត្រូវចំពោះសំណង់ជាប់នឹងដីមិនមែនមានតែកម្មសិទ្ធិករទេ ដែលជាអ្នកទទួលខុសត្រូវ តែមានបុគ្គលផ្សេងទៀតដែលត្រូវទទួលខុសត្រូវ ហើយការទទួលខុសត្រូវត្រូវផ្អែកទៅលើល័ក្ខខ័ណ្ឌដែលច្បាប់បានកំណត់ខុសៗពីគ្នា។ លើសពីនេះទៀតសំណង់ជាប់នឹងដីមិនមែនសំដៅទៅលើសំណង់ជាអាគារ ផ្ទះ ខុនដូតែប៉ុណ្ណោះទេ តែស្ពាន និងសំណង់មួយចំនួនទៀតក៏បានចាត់ទុកថាជាសំណង់ជាប់នឹងដីដែរ។ ហើយបន្ថែមពីលើល័ក្ខខ័ណ្ឌចំបងៗនៃអំពើអនីត្យានុកូលចំពោះការទទួលខុសត្រូវសំណង់ជាប់នឹងដីមានល័ក្ខខ័ណ្ឌក្នុងករណីនីមួយៗបន្ថែមពីលើនេះទៀត។

ដូចនេះ ការទទួលខុសត្រូវលើសំណង់ជាប់នឹងដីទាមទារឲ្យពលរដ្ឋគ្រប់រូបត្រូវធ្វើការយល់ដឹងឲ្យបានច្បាស់លាស់ និងទូលំទូលាយ ដើម្បីជៀសវាងការទាមទារសំណងខុសដែលនាំឲ្យខាតបង់នូវពេលវេលា និងលុយកាក់ក្នុងការទាមទារសំណងតាមនីតិវិធីផ្សេងៗរបស់តុលាការជាដើម។

សរុបសេចក្ដីមក ការទទួលខុសត្រូវលើអំពើអនីត្យានុកូល គឺជាបញ្ហាចំបងមួយដែលបច្ចុប្បន្នកំពុងតែជួបប្រទះ ហើយក៏មានសារៈសំខាន់សម្រាប់សង្គម ហើយទាមទារទាំងប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូលឲ្យមានស្មារតីភ្ញាក់រលឹក ចុះទទួលខុសត្រូវ និងទទួលស្គាល់នូវកំហុសរបស់ខ្លួនដោយគោរពច្បាប់ មានសីលធម៌ សុជីវធម៌នៅក្នុងការរស់នៅប្រកបដោយសុខដុមរមនា និងជាពិសេសរួបរួមគ្នាក្នុងការពង្រឹងឯកភាពជាតិ អធិតេយ្យ បូរណភាពទឹកដីដែលជាដែនដីអច្ឆរិយៈ និងជម្រុញឲ្យប្រទេសយើងឆ្ពោះទៅរកការរីកចម្រើនលូតលាស់សម្បូររុងរឿងជានិច្ចនិរន្តន៍។

# អនុសាសន៍

# អនុសាសន៍

ដោយឆ្លងកាត់តាមការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំកន្លងមកឃើញថា ការទទួលខុសត្រូវលើអំពើអនីត្យានុកូលចំពោះករណីសំណង់ជាប់នឹងដីនៅក្នុងប្រទេសយើង គឺកើតមានឡើងជាច្រើនដែលបង្កឲ្យមាននូវការខូចខាតកើតមានទៅដល់បុគ្គលដែលជាជនរងគ្រោះមិនថា ជាលក្ខណៈតិចតួចក្តី ឬលក្ខណៈធំដុំក្តី ហើយនៅក្នុងករណីមួយចំនួនសំណងនៃព្យសនកម្មមិនមានលក្ខណៈស្របទៅតាមការកំណត់របស់ច្បាប់នោះទេ ដោយសារតែពេលខ្លះជនរងគ្រោះមិនទទួលបាននូវសំណងព្យសនកម្មទៅតាមទំហំនៃការខូចខាតរបស់ខ្លួន ឬពេលខ្លះទំហំនៃសំណងព្យសនកម្មមិនសមាមាត្រទៅនឹងទំហំនៃការខូចខាតរបស់ជនរងគ្រោះ។

ម្យ៉ាងវិញទៀត បញ្ហាទាក់ទងទៅនឹងព្យសនកម្មដែលកើតឡើងដោយសំណង់ជាប់នឹងដីនេះជាផលវិបាកមួយដែលកើតមានឡើងនៅក្នុងសង្គមនាពេលបច្ចុប្បន្ន ហើយក៏បានហុចនូវផលអវិជ្ជមានដែរ ដោយហេតុថាទំហំនៃព្យសនកម្មរបស់វាមានការប៉ះពាល់ខ្លាំងទៅដល់ជនរងគ្រោះច្រើននាក់ដែលយើងមិនគួរមើលរំលង។ រាជរដ្ឋាភិបាល ព្រមទាំងស្ថាប័នដែលពាក់ព័ន្ធគួរតែចាត់វិធានការទៅលើបញ្ហាមួយនេះឲ្យបានជាក់លាក់ ដើម្បីជានាទៅដល់សុខសុវត្ថិភាពរបស់ប្រជាជន និងដើម្បីបង្ការកុំឲ្យមាននូវហានិភ័យគ្រោះថ្នាក់ណាមួយកើតមានឡើង ដោយសារតែសំណង់ជាប់នឹងដីនេះដែរ។ មិនតែប៉ុណ្ណោះគួរតែបង្កើតឲ្យមាននូវបញ្ញត្តិច្បាប់ ឬវិធានការគ្រប់គ្រងឲ្យបានតឹងរ៉ឹង និង មានភាពច្បាស់លាស់ពាក់ព័ន្ធនឹងការទទួលខុសត្រូវទៅលើសំណងព្យសនកម្មដែលកើតមានឡើងដោយសារតែសំណង់នេះដើម្បីឲ្យជនរងគ្រោះទទួលបាននូវសំណងនៃការខូចខាតពីជនដែលបង្កឡើងដោយសមរម្យ និងស្របទៅតាមការកំណត់របស់ច្បាប់។

ក្រៅពីនេះទៅទៀត បុគ្គលគ្រប់រូបមិនថារូបវន្តបុគ្គល ឬនីតិបុគ្គលនោះទេក៏គួររួមចំណែកនៅក្នុងបញ្ហាមួយនេះដោយគួរតែមានការប្រុងប្រយ័ត្ន និងគោរពទៅតាមការកំណត់របស់ច្បាប់នៅក្នុងការសាងសង់សំណង់ដើម្បីជួយបង្ការ និងកាត់បន្ថយនូវការកើតឡើងនូវការខូចខាតណាមួយដែលពាក់ព័ន្ធទៅនឹងសំណង់ទៅកាន់ជនរងគ្រោះ ព្រមទាំងជួយកាត់បន្ថយនូវបញ្ហាដែលកើតមានឡើងនៅក្នុងសង្គមបានមួយចំណែកផងដែរ។ ហេតុដូចនេះក្រៅពីរាជរដ្ឋាភិបាល យើងគ្រប់រូបក៏មានតួនាទីសំខាន់នៅក្នុងបញ្ហាសំណង់នេះដែរ ព្រោះដើម្បីកុំឲ្យមានជនរងគ្រោះណាមួយដែលទទួលរង

នូវការខូចខាតដោយសារតែបញ្ហាសំណង់នេះ និងដើម្បីកុំឲ្យបុគ្គលណាម្នាក់ក្លាយជាជនបង្កឲ្យកើតមាននូវព្យសនកម្មតទៅទៀត។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ច្បាប់ស្តីពីធានារ៉ាប់រង, នស/រកម/០៨១៤/០២១, ២១ កក្កដា ២០១៤។

ប្រកាសស្តីពី ការប្រមូលពន្ធលើអចលនទ្រព្យ, លេខ ៤៩៣ សហវ.ប្រក, ១៩ កក្កដា ២០១០។


## ឯកសារផ្សេងៗ


កេត សុជាតិ. ២០១៥. *នីតិរដ្ឋប្បវេណី*. ភ្នំពេញ។

ក្រុមការងារនៃអនាគតគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. ២០១៣. *សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណីភាគ១-២*. រាជធានីភ្នំពេញ។

ញឹក វុទ្ធី. គ្មានកាលបរិច្ឆេទ. *នីតិកាតព្វកិច្ច ភាគទី២*. ភ្នំពេញ។

តូយ៉ូហ៊ីរ៉ូ, ណូមឹរ៉ា. ២០១៤. *សេចក្ដីផ្ដើមនីតិរដ្ឋប្បវេណី*. បកប្រែដោយ សរ សិនិរ៉ា និងស៊ឹម វីរៈ,កែសម្រួលដោយ Matsubara Sadao, Kanetake Emiko, អ៊ាន ឆវីដា, ង៉ែត ណារ័ត្ន, សួន ពលាក់, និងសោ រតនា. រាជធានីភ្នំពេញ។

ទីស្ដីការគណៈរដ្ឋមន្ត្រី, ២០០៧. *សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី*, រាជធានីភ្នំពេញ។

ម៉ឹក សំណាប់. ២០១៧. *កិច្ចសន្យាមៅការ*. ដកស្រង់ចេញពី www.bizdoctors.asia. ថ្ងៃទី ២៥ ឧសភា ២០១៨។

ម៉ូរិ តូម៉ូយ៉ា. ២០១៤. *អំពើអនីត្យានុកូល (ទ្រឹស្ដីនៃល័ក្ខខ័ណ្ឌ)*. បទបង្ហាញនៅក្នុងសិក្ខាសិលានៅកម្ពុជានៅ, ខែមិនា)។

សួស ចំរើន. ២០០៣. *គ្រប់គ្រងសំណង់* ។

ស្រី វណ្ណធី. ២០១៦. *នីតិរដ្ឋប្បវេណី*. បោះពុម្ពលើកទី២. រាជធានីភ្នំពេញ។

ស្រី វណ្ណធី. ២០១៦. *នីតិរដ្ឋប្បវេណី ភាគ២*. បោះពុម្ពលើកទី២. ភ្នំពេញ។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. ២០១៣. *សៀវភៅណែនាំស្តីពីពន្ធលើអចលនទ្រព្យ*, ភ្នំពេញ។

# ឧបសម្ព័ន្ធ